**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ស្រាវជ្រាវពីថ្ងៃទី ១៤ ខែ មេសា ដល់ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៥

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ: **ឈុន ម៉ុនឡេង**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ:
ជំនាន់ទី ៨

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈុន ម៉ុនឡេង** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី៨ ឆ្នាំសិក្សា ២០១៤-២០១៥ នៃសកលវិទ្យាល័យនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងធំធេងចំពោះអ្នកម្តាយ **គឹម នាង** និង សូមឧទ្ទិសដល់ លោកឪពុក **អាត់ ម៉េងឈុន** ដែលតស៊ូទាំងយប់ទាំងថ្ងៃដើម្បីឲ្យកូនបានសិក្សារៀនសូត្ររហូតដល់ពេលនេះ។

កូនសូមអនុញ្ញាតិសំដែងនូវការគោរព ដឹងគុណ ដ៏ជ្រាលជ្រៅចំពោះ លោកឪពុក និង អ្នកម្តាយ តាមរយៈការប្រណម្យម្រាមដៃទាំងដប់ សំពះដល់លោកទាំងពីរ។

កូនមិនអាចភ្លេចឡើយនូវគុណានូបការ នៃលោកទាំងពីរ ដែលបានផ្តល់កំណើតដល់រូបកូន និង បានចិញ្ចឹមបីបាច់ ថៃរក្សា អប់រំ កូនឲ្យក្លាយជាធនធានល្អសម្រាប់គ្រួសារ និង សង្គមជាតិ។ លោកទាំងពីរ ខិតខំ មិនខ្លាចនឿយហត់ ពុះពារឧបសគ្គគ្រប់បែបយ៉ាង ទាំងកំលាំងកាយកំលាំងចិត្ត ដើម្បីចិញ្ចឹមថៃរក្សារូបកូនចាប់តាំង ពីនៅក្នុងផ្ទៃ រហូតដល់កូនបានធំ។ លើសពីនេះទៀតពេលដែលរូបកូនបានចាប់កំណើត លោកទាំងពីររឹតតែពិបាកក្នុងការខិតខំពុះពារគ្រប់បែបយ៉ាង ទោះបីការងារទាំងនោះអាចបង្កគ្រោះដល់ជីវិត ក៏លោកទាំងពីរមិនខ្លាចរញ្ជើតដែរ ព្រោះដើម្បីចិញ្ចឹមជីវិតកូនឲ្យរស់នៅបានសុខស្រួល និង ផ្គត់ផ្គង់ ឲ្យកូនបានសិក្សារៀនសូត្រ មានចំណេះដឹង ដើម្បីក្លាយជាមនុស្សម្នាក់ដែលសង្គមជាតិត្រូវការ ក្នុងការអភិវឌ្ឍប្រទេសជាតិ និង គ្រួសារ ។ ជាពិសេសគុណរបស់លោកទាំងពីរ គឺ មិនអាចយកអ្វីមក ប្រៀបធៀបជាមួយបានទេសម្រាប់រូបកូន។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្ឌិត **សឿន សោភ័ណ** ដែលលោកបាន ជួយដឹកនាំ ជ្រោមជ្រែង ត្រួតពិនិត្យ កំឡុងពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះដោយ រលូន។ ប៉ុន្តែបើគ្មានវត្តមានរបស់សាស្រ្តចារ្យទេ ប្រហែលជាខ្ញុំបាទក៏មិនអាចសម្រេចបាននូវភារកិច្ចមួយនេះបានទេ គឺក៏ព្រោះតែលោកបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការ ពិនិត្យ និង កែលម្អនូវសារណាមួយនេះឲ្យមានលក្ខណៈល្អប្រសើរ។

ជាចុងក្រោយនេះខ្ញុំបាទសូមលើកម្រាមដៃទាំងដប់ ប្រណម្យបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់នៅលើលោកនេះ សូមតាមថៃរក្សា ការពារ ដល់អ្នកមានគុណ និង សាស្រ្តចារ្យទាំងអស់ ឲ្យជួបតែសេចក្តីសុខ អាយុយឺនយូរ សុខភាពបរិបូរណ៍ និង សម្រេចគ្រប់ភារកិច្ច។

# អារម្ភកថា

រាជរដ្ឋាបាលភិបាលកម្ពុជាបានបង្ហាញពីឆន្ទៈរបស់ខ្លួនយ៉ាងមោះមុត ក្នុងការសម្រេចឲ្យបានក្នុងការអនុវត្តគោលការណ៍វិមជ្ឈការ ឃុំ សង្កាត់ ដើម្បីធានាដល់ការចូលរួមចំណែក ការអភិវឌ្ឍន៍មូលដ្ឋានតាមគោលការណ៍ នៃការអនុវត្តតាមបែបប្រជាធិបតេយ្យ គឺ ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ការបង្កើនសុខុមាលភាព និងការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន ដែលជាផ្នែកមួយក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។

រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តនូវគោលនយោបាយ កំណែទម្រង់វិមជ្ឈការ តាមរយៈការបង្កើត ឲ្យមានក្រុមប្រឹក្សា ឃុំ សង្កាត់ ដោយអនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានអនុម័តនៅឆ្នាំ ២០០១។ ជាងនេះទៅទៀត ច្បាប់រៀបចំអង្គការនេះបានតម្រូវឲ្យរដ្ឋបាលឃុំ សង្កាត់ គ្រប់គ្រងតាមគោលការណ៍ ដើម្បីសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រព័ន្ធរដ្ឋបាលសាធារណៈដែលល្អ គឺ ឆ្លើយតបទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការរស់នៅ និង ប្រកបរបរចិញ្ចឹមជីវិតជាក់ស្តែង ហើយមានតម្លាភាព គណនេយ្យភាព យុត្តិធម៌ សមធម៌ និង គ្មានការរើសអើម ទើបប្រជាជនទទួលបានផលប្រយោជន៍ នៃការធ្វើកំណែទម្រង់វិមជ្ឈការរបស់រាជរដ្ឋាភិបាល។ ទោះបីជាដំណើរការកំណែទម្រង់វិមជ្ឈការមានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ក៏ក្រុមប្រឹក្សា ឃុំ សង្កាត់ បានដំណើរការការងាររបស់ខ្លួនដោយរលូនអស់រយៈពេលជាង១០ ឆ្នាំកន្លងមកហើយ។

បើយើងគិតរហូតមកដល់ពេលនេះការបោះឆ្នោតក្រុមប្រឹក្សា ឃុំ សង្កាត់ មានចំនួនបីដង គឺ ការបោះឆ្នោតលើកទី១ នៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០២ ដែលមាន ១៦២១ឃុំ សង្កាត់ ហើយលើកទី២ នៅថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ ដែលមាន ១៦៣៣ ឃុំ សង្កាត់ និង លើកទី៣ នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១២ ដែលមាន ១៦៣៣ ឃុំ សង្កាត់ដដែល។

ខ្ញុំបាទគិតថាសារណានេះពិតជាមានការខុសឆ្គង និង ការខ្វះខាត ជាក់ជាមិនខាន ខ្ញុំបាទរងចាំទទួលដោយក្តីរីករាយ និង អំណរគុណយ៉ាងខ្លាំងនូវ មតិរិះគុណទិតៀន ដើម្បីស្ថាបនាកែលម្អពីសំណាក់សាស្ត្រាចារ្យ និស្សិត និង មិត្តអ្នកអាន ដើម្បីធ្វើអោយសារណានេះកាន់តែល្អប្រសើរ សម្រាប់ជាឯកសារសិក្សាជ្រាវស្រាវដ៏ល្អឆ្លើយតបឲ្យកាន់តែសុក្រិតទៅ និង បច្ចុប្បន្នភាពនៃសង្គម។

# មាតិកា


**សេចក្ដីថ្លែងអំណរគុណ** ........ i

**អារម្ភកថា** ........ ii

**សេចក្ដីផ្ដើម**

**១. លំនាំបញ្ហា** ........ ១

**២. ចំណោទបញ្ហា** ........ ២

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ** ........ ២

**៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ** ........ ៣

**៦. វិធីសាស្រ្តស្រាវជ្រាវ** ........ ៣

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣

**ជំពូកទី ១ : ទស្សនៈទានទូទៅស្ដីពីវិមជ្ឈការ**

១.១ និយមន័យ ........ ៥

១.២ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ ........ ៥

១.៣ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិជម្ឈការ ........ ៦

១.៤ ទិសដៅវិមជ្ឈការ ........ ៧

១.៤.១ ការផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ ........ ៧

១.៤.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃការរស់នៅ ........ ៨

១.៥ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់ ........ ៩

១.៦ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់........................................................................................................១២

១.៦.១ ក្រុមប្រឹក្សាឃុំ សង្កាត់........................................................................................................១២

១.៦.១.១ អាណត្តិ និង ការរំសាយ........................................................................................ ១៣

១.៦.១.២ តួនាទី និង សមត្ថកិច្ច........................................................................................ ១៣

១.៦.១.៣ ទំនាក់ទំនងក្នុងប្រទេស និង ក្រៅប្រទេស........................................................................១៦

១.៦.១.៤ ព្រំដែនអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់........................................................................១៦

១.៦.២ មេឃុំ ចៅសង្កាត់........................................................................................................ ១៧

១.៦.៣ ជំទប់ទី១-ទី២ ឬ ចៅសង្កាត់ទី១-ទី២........................................................................................១៩

១.៦.៤ គណៈកម្មាធិការ........................................................................................................១៩

១.៦.៥ ស្មៀនឃុំ សង្កាត់........................................................................................................២០

១.៦.៦ មេភូមិ........................................................................................................២១

## ជំពូកទី ២ : ដំណើរការអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

២.១ លិខិតរដ្ឋបាល ឃុំ សង្កាត់........................................................................................................២៣

២.២ កិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់........................................................................................................២៥

២.២.១ ការត្រៀមរៀបចំកិច្ចប្រជុំ........................................................................................................២៦

២.២.២ ការប្រព្រឹត្តិទៅនៃកិច្ចប្រជុំ........................................................................................................២៦

២.៣ ប្រភពចំណូល ឃុំ សង្កាត់........................................................................................................២៧

២.៣.១ ចំណូលផ្ទាល់........................................................................................................២៨

២.៣.២ ចំណូលពីមូលនិធិឃុំ សង្កាត់........................................................................................................២៨

២.៣.៣ ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ........................................................................................................២៨

២.៤ ថវិកាឃុំ សង្កាត់.......................................................................................................២៩

២.៥ ប្រព័ន្ធទូទាត់ គណនេយ្យ និង លទ្ធកម្ម ឃុំ សង្កាត់ .................................................................... ៣០

២.៦ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់...........................................................................................៣២

២.៦.១គោលការណ៍សំខាន់ៗការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគឃុំ សង្កាត់ ........ ៣២

២.៦.២ តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធ ........................................................................៣៣

២.៦.៣ វដ្តនៃផែនការអភិវឌ្ឍឃុំ សង្កាត់ ............................................................................ ៣៦

២.៦.៤ វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់............................................................................. ៣៨

២.៧ ការអនុវត្ត និង តាមដាន ផែនការឃុំ សង្កាត់..........................................................................៤០

## ជំពូកទី ៣ : របកគំហើញនៃការស្រាវជ្រាវ

៣.១ សមិទ្ធផល គិតត្រឹមឆ្នាំ ២០១១............................................................................................៤២

៣.១.១ ការធ្វើប្រតិភូកម្មមុខងារជាភ្នាក់ងារទៅឲ្យ ឃុំ សង្កាត់.......................................................៤២

៣.១.២ ការរៀបចំតាក់តែងលិខិតបទដ្ឋាន ............................................................................ ៤៣

៣.១.៣ ហិរញ្ញវត្ថុឃុំ សង្កាត់................................................................................................ ៤៣

៣.១.៤ ជំនួយវិភាគន៍ផ្តល់ឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ ................................................................៤៥

៣.១.៥ កត្តាគោលនយោបាយ ...............................................................................................៤៥

៣.១.៦ គណនេយ្យភាព និង តម្លាភាព...................................................................................៤៥

៣.១.៧ ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន.......................................៤៦

៣.២ បញ្ហាប្រឈម.................................................................................................................៤៦

៣.២.១ ការចូលរួម និង ភាពជាម្ចាស់.....................................................................................៤៦

៣.២.២ ធនធានហិរញ្ញវត្ថុ .................................................................................................... ៤៧

៣.២.៣ ធនធានមនុស្ស និង ការអភិវឌ្ឍសមត្ថភាព ........ ៤៧

៣.២.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ ........ ៤៧

៣.៣ ដំណោះស្រាយ ........ ៤៨

៣.៣.១ ការចូលរួម និង ភាពជាម្ចាស់ ........ ៤៨

៣.៣.២ ធនធានហិរញ្ញវត្ថុ ........ ៤៨

៣.៣.៣ ធនធានមនុស្សនិងការអភិវឌ្ឍសមត្ថភាព ........ ៤៩

៣.៣.៤ ប្រព័ន្ធ និង រចនាសម្ព័ន្ធ ........ ៤៩

**សេចក្ដីសន្និដ្ឋាន** ........ ៥០

**អនុសាសន៍** ........ ៥១

**ឯកសារយោង** ........ ៥៣

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## លំនាំបញ្ហា

ការបង្កើតឡើងនូវក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ បាននាំយកមកនូវដំណើរការបែបប្រជាធិបតេយ្យ និង ការធ្វើសេចក្តីសម្រេចចិត្ត គឺប្រជាពលរដ្ឋមានសិទ្ធិចូលរួមដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាង។ ដំណើរការរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ និង លើកឡើងនូវតម្រូវការរបស់ប្រជាពលរដ្ឋ និង លើកកម្ពស់ការផ្តល់សេវាសាធារណៈ និង កិច្ចអភិវឌ្ឍមូលដ្ឋាន។ ក្រុមប្រឹក្សាឃុំ សង្កាត់ ជាសេនាធិការរបស់រាជរដ្ឋាភិបាល លើសពីនេះទៅទៀតក្រុមប្រឹក្សា ឃុំ សង្កាត់ គឺនៅជិត ប្រជាពលរដ្ឋ និង យល់ច្បាស់ពីតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋក្រីក្រ ហើយគាត់អាចរៀបចំកម្មវិធី ដើម្បី កែលម្អជីវភាពរស់នៅរបស់ជនក្រីក្រទាំងនោះឲ្យទទួលបានលទ្ធផលល្អប្រសើរជាងមុន។ បើយើងពិនិត្យទៅលើការធ្វើកំណែទម្រង់រដ្ឋបាល ឃុំ សង្កាត់ បែបវិមជ្ឈការ ហាក់បីដូចជា ប្រជាពលរដ្ឋទទួលបាននូវអត្ថប្រយោជន៍ និង ការឆ្លើយតបយ៉ាងមានប្រសិទ្ធភាព ទៅនិងតម្រូវការរបស់ ពួកគាត់ ជាពិសេសថែមទាំងអាចចូលរួមកាត់បន្ថយនូវភាពក្រីក្រ និង នាំឲ្យមានការអភិវឌ្ឍន៍ដល់ប្រទេសជាតិថែមទៀតផង។ កំណែទម្រង់វិមជ្ឈមានគោលបំណង លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និង កែលម្អជីវភាពរស់នៅរបស់ប្រជាជន។ ហើយប្រជាជនទទួលបានឱកាសកាន់តែច្រើនក្នុងការធ្វើ សេចក្តីសម្រេចចិត្តលើបញ្ហានៅមូលដ្ឋាន ដែលប៉ះពាល់មកលើជីវភាពរស់នៅរបស់ពួកគាត់។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ សង្កាត់ របស់ខ្លួន ហើយត្រូវធានាឲ្យសហគមន៍នៅតាមមូលដ្ឋានបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច របស់ក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងត្រឹមត្រូវ។ ការចូលរួមនេះមានសារៈសំខាន់ណាស់ ពីព្រោះរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ តែងមានផលប៉ះពាល់មកលើប្រជាពលរដ្ឋរបស់ខ្លួន ដូចជាការពង្រីកផ្លូវ និង ការសាងសង់ផ្លូវជាដើម។ បើយើងសង្កេតអំពី កំណែទម្រង់វិមជ្ឈការ ឃុំ សង្កាត់ ដូចជាអាចធានានូវការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានបានយ៉ាងស្រួល និង គ្មានទំនាស់អ្វីកើតឡើងនោះទេ ប៉ុន្តែបែរជា នៅតាមមូលដ្ឋាន ប្រជាពលរដ្ឋហាក់បីដូចជា ទទួលរងនូវផលប៉ះពាល់ជាច្រើនពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅវិញ។

## ចំណោទបញ្ហា

ការសិក្សាអំពីប្រធានបទខាងលើ អំពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការវាបង្ហាញឲ្យឃើញនូវបង្ហាញចោទដូចខាងក្រោមៈ

- តើការកំណែទម្រង់វិមជ្ឈការ ឃុំ សង្កាត់ អាចឲ្យប្រជាពលរដ្ឋនៅតាមមូលដ្ឋានទទួលបាននូវសារៈសំខាន់អ្វីខ្លះ ?
- តើវិមជ្ឈការ ឃុំ សង្កាត់អាចចូលរួមចំណែកក្នុងកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋានដែរឬ ទេ?
- តើការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ដូចម្តេចទើបបង្ហាញពីតម្លាភាព និង ប្រសិទ្ធភាព?

## គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះគឺមានគោលបំណងរកឲ្យឃើញថា ការងារអនុវត្ត និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និង សមធម៌ដែរឬ ទេ?

ហើយការសិក្សាស្រាវជ្រាវនេះដើម្បីធ្វើការវាយតម្លៃអំពី ៖

- ការបំពេញតួនាទី និង ការគ្រប់គ្រងនៅមូលដ្ឋាន
- កំណត់ពីសមត្ថភាពរបស់មន្ត្រី ក្នុងការអនុវត្តការងារ
- វាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន

របកគំហើញខាងលើនេះ និង ប្រើប្រាស់ ដើម្បីធ្វើការកែលម្អនូវរចនាសម្ព័ន្ធថ្មីនៅថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ ចំណុចដែលប៉ះពាល់ដល់ការងារ និង ប្រជាជន ព្រោះបើការគ្រប់គ្រងនៅថ្នាក់មូលដ្ឋានមានលក្ខណៈ មិនអំណោយផល វានិងជះឥទ្ធិពលដល់ថ្នាក់ជាតិក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិជាក់ជាមិនខាន។

## ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺ សំដៅទៅលើ ការគ្រប់គ្រងនៅ ឃុំ សង្កាត់ ដោយវិធីណាទើបប្រកបដោយតម្លាភាព និង ឆ្លើយតបទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីមានការអភិវឌ្ឍនៅតាម ឃុំ សង្កាត់របស់ខ្លួន។ ហេតុផលដែលរាជរដ្ឋាភិបាល ធ្វើកំណែទម្រង់វិជម្មការ ឃុំ សង្កាត់នេះឡើង និង សម្មិទិផលដែលការគ្រប់គ្រងឃុំ សង្កាត់ទទួលបាន នៅក្នុងឆ្នាំ ២០០៧-២០១១ ដោយផ្អែកទៅលើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១។

## សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

លទ្ធផលដែលទទួលបានក្នុងការស្រាវជ្រាវនេះ វាអាចជាចំណេះដឹង និង គោលការណ៍ ក្នុងការអភិវឌ្ឍប្រទេសជាតិ។ ហើយក៏ទុកជាឯកសារសម្រាប់ឲ្យ និស្សិត ប្រជាពលរដ្ឋ និង មន្ត្រីរាជការទាំងអស់បានយល់ និង ដឹងអំពីសកម្មភាពប្រព្រឹត្តយ៉ាងណា ទើបធានានូវអភិបាលកិច្ចល្អនៅថ្នាក់ឃុំសង្កាត់ ដែលជាកត្តានាំឲ្យមានការអភិវឌ្ឍប្រទេសជាតិ។

## វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីប្រមូលពត៌មាន យកមកធ្វើការចងក្រងជាសារណានេះបានឲ្យល្អ គឺមានការធ្វើសកម្មភាពស្រាវជ្រាវដូចជា៖

- នៅបណ្ណាល័យ
- ដកចេញពីសៀវភៅខ្លះដែលពាក់ព័ន្ធនិងប្រធានបទ
- តាមចំណេះដឹងខ្ញុំបាទដែលបានសិក្សាកន្លងមក
- ដកស្រង់ចេញពីប្រសាសន៍របស់សាស្ត្រាចារ្យ

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- មាតិកា

- សេចក្តីផ្តើម

- ជំពូកទី១ : ជំពូកនេះ គឺ បង្ហាញអំពី និយមន័យ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ ហេតុផលនៃការគ្រប់គ្រងតាមបែបវិមជ្ឈការ ទិសដៅនៃវិមជ្ឈការ ប្រវត្តិនៃការធ្វើវិមជ្ឈការឃុំ សង្កាត់ និង រចនាសម្ព័ន្ធនៃរដ្ឋបាល ឃុំ សង្កាត់។

- ជំពូកទី២ : ជំពូកនេះ គឺ បង្ហាញអំពី លិខិតរដ្ឋបាល កិច្ចប្រជុំក្រុមប្រឹក្សា ប្រភពចំណូល ឃុំ សង្កាត់ ថវិកាឃុំ សង្កាត់ ប្រព័ន្ធទូទាត់ គណនេយ្យ និង លទ្ធកម្ម ឃុំ សង្កាត់ លើសពីនេះក៏បង្ហាញអំពីប្រព័ន្ធកសាងផែនការឃុំ សង្កាត់ ការអនុវត្ត និង ការតាមដាន ផែនការឃុំ សង្កាត់ ផងដែរ។

-ជំពូកទី៣ : ជំពូកនេះគឺចង់បង្ហាញអំពី សមិទ្ធផលរបស់ឃុំ សង្កាត់ គិតត្រឹមឆ្នាំ ២០១១ បញ្ហាប្រឈម និង ដំណោះស្រាយ ដើម្បីធានាឲ្យការអនុវត្តនៅថ្នាក់មូលដ្ឋានទទួលបានប្រសិទ្ធភាព។

- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១

# ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

## ១.១ និយមន័យ

វិមជ្ឈការ ឃុំ សង្កាត់ មានន័យថា សិទ្ធិអំណាច ការទទួលខុលត្រូវ និង ធនធានមួយចំនួនត្រូវបានផ្ទេរពី រដ្ឋបាលថ្នាក់ជាតិ ទៅឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋតាមលក្ខណៈប្រជាធិបតេយ្យ។

## ១.២ ទិដ្ឋភាពសំខាន់ៗនៅក្នុងវិមជ្ឈការ

ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ មានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន។ ហើយប្រជាពលរដ្ឋ ត្រូវបានផ្តល់សិទ្ធិ និង ការទទួលខុសត្រូវ ឲ្យចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន ឃុំ សង្កាត់ របស់ខ្លួន។ លើសពីនេះទៅទៀត ក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ដូច្នេះ ក្រុមប្រឹក្សានេះ ជាតំណាងឲ្យប្រជាពលរដ្ឋ នៅក្នុង ឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សា ឃុំ សង្កាត់ មានអាណត្តិ៥ឆ្នាំ ហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សា ឃុំ សង្កាត់ ថ្មីចូលកាន់តំណែង។ ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានផ្តល់ការទទួលខុសត្រូវ និង ភារកិច្ចជាច្រើន ដែលខុសប្លែកទាំងស្រុងពី ការទទួលខុសត្រូវ និង ភារកិច្ចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ កាលពីមុនបោះឆ្នោតឆ្នាំ ២០០២។ ជាពិសេស ភារកិច្ចសំខាន់បំផុតរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ គឺ អភិវឌ្ឍ ឃុំ សង្កាត់ ហើយលើកកម្ពស់សុខុមាលភាព និង មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនថែមទៀតផង។ ក្រុមប្រឹក្សា ឃុំ សង្កាត់ត្រូវធានាឲ្យបានថា សហគមន៍នៅមូលដ្ឋានចូលរួមយ៉ាងពេញលេញ និង សកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ និង សេចក្តីសម្រេចនានា ដែលមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដូចជាសេចក្តីសម្រេចលើការប្រើប្រាស់ធនធាន សម្រាប់ការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនជាដើម។ ការធ្វើសេចក្តីសម្រេចដែលមានការចូលរួមពីប្រជាពលរដ្ឋ ទើបសេចក្តីសម្រេចនោះទទួលបាននូវប្រសិទ្ធភាពខ្ពស់។

ហេតុនេះជាការពិតណាស់ អ្វីក៏ដោយបើគ្មានការចូលរួមពីប្រជាពស្ត្រនោះទេ ទោះបីរដ្ឋខិតខំ

ប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏វាមិនអាចទៅរួចដែរ ដូចជាការងារអភិវឌ្ឍនានាជាដើម។ ឃើញស្រាប់ ហើយបើរាស្ត្រគ្មានលទ្ធភាពនិងចូលរួមនោះទេ ការអភិវឌ្ឍពិតប្រាកដវាបានត្រឹមតែ អភិវឌ្ឍខ្លួនឯង ប៉ុណ្ណោះ។ ឧទាហរណ៍ៈ ក្រុមមន្ត្រីដែលទទួលភារកិច្ចតួនាទីជាអ្នកជួយរាស្ត្រ សម្រាប់ធ្វើការអភិវឌ្ឍកិច្ច ការណាមួយ ហើយរាស្ត្រមើលឃើញថា មន្ត្រីនោះបានអភិវឌ្ឍខ្លួនឯង ជាជាងការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានរបស់ខ្លួនគ្រប់គ្រង ដែលវាបញ្ជាក់ថាការអភិវឌ្ឍដែលខ្វះដៃគូរ គឺ មិនទទួលបាននូវប្រសិទ្ធភាពទេ។

## ១.៣ ហេតុផលនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ តាមបែបវិមជ្ឈការ

ប្រទេសដែលអនុវត្តតាមគោលការណ៍វិមជ្ឈការ នាំមកនូវការរីចម្រើនខាងសេដ្ឋកិច្ចកាន់តែខ្លាំងឡើងយ៉ាងឆាប់រហ័សក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង ដោះស្រាយក្នុងការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ។ ហើយការផ្តល់សេវាសាធារណៈកាន់តែប្រសើរ ឡើងថែមទៀត ក្នុងនោះ គឺ មានការផ្តោតយកចិត្តទុកដាក់ថែមទៀត ទៅលើ ការធ្វើប្រតិភូកម្ម ថវិកាភារកិច្ច និង ការទទួលខុសត្រូវផ្ទាល់នៅមូលដ្ឋាន។ ក្រៅពីនេះ គឺ ការធ្វើឲ្យប្រសើរឡើងថែមទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តទាំងឡាយបានត្រឹមត្រូវ នៅតាមទីកន្លែង និងពេលវេលា ព្រោះមានការចូលរួម ដោយប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់។ ហើយនរណានិងទទួលបានផលប្រយោជន៍ទាំងនោះ?

វិមជ្ឈការ ឃុំ សង្កាត់ នេះ គឺ ត្រូវបានអ្នកនយោបាយទាំងឡាយ ផ្តួចផ្តើមឡើង និងអនុម័តយល់ស្របអំពី កំណែទម្រង់វិមជ្ឈការនេះ ដូចនេះអ្នកនយោបាយ និង ទទួលបានប្រយោជន៍ពីវាជាមិនខាន ( បើមិនដូច្នេះទេ ពួកគេនិងមិនយល់ព្រមធ្វើការកំណែទម្រង់វិមជ្ឈការនោះទេ )។ ក្រៅពីអ្នកនយោបាយទាំងនេះ គឺ មានប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ព្រោះវិមជ្ឈការ ផ្តល់នូវអង្គភាពរដ្ឋបាលពោលពេញដោយការប្រជែងខ្លាំងក្លាដែលអាចឆ្លើយតបបានច្រើនជាងមុនចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ព្រោះពួកគេចង់បានការគាំទ្រពីប្រជាពលរដ្ឋនៅមូលដ្ឋានរបស់គេ។

ដូចនេះរាជរដ្ឋាភិបាលបានខិតខំ ធ្វើកំណែទម្រង់ការគ្រប់គ្រងវិមជ្ឈការ នៅឃុំ សង្កាត់ ដើម្បីទទួលបាននូវសម្មទ្ធិផលជាច្រើនដូចជា៖

- កាត់បន្ថយនូវភាពមិនអើពើចំពោះការអភិវឌ្ឍនៅមូលដ្ឋាន
- ជំរុញឲ្យមានការចូលរួមនិងសកម្មភាពរួបរួមផ្សេងៗ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឲ្យកាន់តែខ្លាំងឡើង

- ពង្រឹងការឆ្លើយតប ឲ្យបានឆាប់រហ័ស និង យល់ច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ
- បង្កើននូវលំហូរព័ត៌មានពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់មូលដ្ឋាន
- ធ្វើឲ្យគម្រោងអភិវឌ្ឍកាន់តែមានចិរភាព
- ពង្រឹងនូវតម្លាភាព
- ជំរុញការទទួលខុសត្រូវឲ្យកាន់តែខ្ពស់
- ធ្វើឲ្យសម្រេចបាននូវកិច្ចការប្រឹងប្រែងថ្មីៗ
- កាត់បន្ថយឥទ្ធិពលអវិជ្ជា
- ធ្វើឲ្យកម្មវិធីអភិវឌ្ឍកាន់តែរលូនជាងមុននៅមូលដ្ឋាន
- កាត់បន្ថយនូវសកម្មភាពពុករលួយ
- ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន

កត្តាទាំងអស់នេះហើយ ដែលធ្វើឲ្យប្រទេសកម្ពុជាយើង បានសម្រេចចិត្តធ្វើការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ឃុំ សង្កាត់ តាមបែបវិជម្ឍការបន្តទៀត។

## ១.៤ ទិសដៅវិមជ្ឈការ

ការធ្វើវិមជ្ឈការនេះ គឺ ដើម្បីផ្តល់ឱកាសដល់ប្រជាពលរដ្ឋឲ្យចូលរួមកាន់តែទូលំទូលាយ នៅក្នុង ការធ្វើសេចក្តីសម្រេចចិត្ត ដែលមានផលប៉ះពាល់ទៅ និង ជីវភាពរស់នៅ និង អនាគតរបស់ខ្លួន។ លើស ពីនេះទៅទៀត ដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃការរស់នៅ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ហើយធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវា ឲ្យនៅជិតប្រជាពលរដ្ឋ និង យល់ច្បាស់អំពីតម្រូវការចាំបាច់របស់ពួកគាត់។

### ១.៤.១ ការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋចូលរួមពេញលេញ

តាមរយៈប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននៅ ឃុំ សង្កាត់ ប្រជាពលរដ្ឋ គ្រប់រូប រួមមាន ស្ត្រី បុរស ចាស់ ក្មេង ជនងាយរងគ្រោះ-ល- មានសិទ្ធិ និង ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពរបស់ ឃុំ សង្កាត់ និង ដំណើរការអភិវឌ្ឍមូលដ្ឋាន ដូចជា ការបញ្ចេញមតិ និង រួមចំណែកតាមមធ្យោបាយផ្សេងៗ។ ហើយ ប្រជាពលរដ្ឋមានសិទ្ធិលើកឡើង អំពីសេចក្តីត្រូវការ និង ផលប្រយោជន៍របស់ខ្លួន តាមរយៈនីតិវិធី និង យន្តការដែលបានកំណត់ក្នុងក្របខណ្ឌវិមជ្ឈការ។ ប្រជាពលរដ្ឋអាចបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលពួកគាត់គិតថា អាចតំណាងឲ្យផលប្រយោជន៍របស់ពួកគាត់បានល្អប្រសើរ

បំផុត និង អាចទំនាក់ទំនងជាមួយពួកគាត់បានយ៉ាងងាយស្រួល ចំពោះការងារដែលពាក់ព័ន្ធនិង ឃុំ សង្កាត់។ហើយប្រជាពលរដ្ឋអាចលើកឡើងពីបញ្ហា និង ផលប្រយោជន៍របស់ពួកគាត់ នៅក្នុងកិច្ចប្រជុំ ឃុំ សង្កាត់ ជាពិសេសតាមដានត្រួតពិនិត្យការអនុវត្តគម្រោងនៅមូលដ្ឋាន និង ការទទួលបានព័ត៌មាន ផ្សេងដែល ពួកគាត់ចង់ដឹង គឺ មានលក្ខណៈងាយស្រួល និង សុក្រឹត្យ។

ការផ្តល់ឱកាសឲ្យប្រពលរដ្ឋចូលរួមពេញលេញ គឺ ជាភារកិច្ចយ៉ាងសំខាន់ របស់ក្រុមប្រឹក្សា ឃុំ សង្កាត់។ ការចូលរួមនេះអាចជួយឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ ស្វែងយល់ពីសេចក្តីត្រូវការ និង ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយធ្វើការឆ្លើយតបឲ្យចំគោលដៅ ហើយប្រសិនបើប្រជាពលរដ្ឋ បានចូលរួម គឺ ពួកគាត់មានអារម្មណ៍ថា ខ្លួនចូលរួមចំពោះការទទួលខុសត្រូវចំពោះការអភិវឌ្ឍ នៅក្នុង មូលដ្ឋានរបស់ខ្លួន ដូចនេះរាល់សេចក្តីសម្រេចគម្រោងអភិវឌ្ឍស្ទើរតែទាំងអស់ គឺ ទទួលបាននូវ ប្រសិទ្ធភាព និង ប្រសិទ្ធផល ។

### ១.៤.២ ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គុណភាពនៃការរស់នៅ

វិមជ្ឈការ ត្រូវបានចាត់ទុកថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជំរុញអភិបាលកិច្ចល្អ។ ហើយអភិបាលកិច្ចល្អ គឺជាការអនុវត្តការងារឲ្យបានសមស្របទៅនិងទិដ្ឋភាពសំខាន់ៗ មួយចំនួន ដូច ខាងក្រោម៖

- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបំពេញការងារដោយអនុលោមទៅតាមច្បាប់ និង លិខិតបទដ្ឋាន នានា ដែលបានកំណត់។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យ ដោយ ប្រជាពលរដ្ឋរបស់ខ្លួន ដូចនេះអ្វីដែលក្រុមប្រឹក្សា ឃុំ សង្កាត់ បានសម្រេច និង អនុវត្ត គឺត្រូវ ទទួលខុសត្រូវយ៉ាងពេញលេញចំពោះប្រជាពលរដ្ឋរបស់ខ្លួន មានន័យថា ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវធ្វើផែនការឲ្យឆ្លើយតបទៅនិង តម្រូវការរបស់ប្រជាពលរដ្ឋ ត្រូវផ្តល់ព័ត៌មានពី របៀបធនធានដែលខ្លួនមាន និងត្រូវធានាថា ធនធានទាំងនោះត្រូវបានប្រើប្រាស់ ដើម្បី បម្រើ ផលប្រយោជន៍របស់ប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព។
- ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវមានតម្លាភាព នៅក្នុងការងារដែលខ្លួនបានបំពេញទាំងអស់ ហើយ ត្រូវជម្រាបជូនសាធារណៈជនពី កិច្ចការនានាដែលខ្លួនបានពិភាក្សា ឬ សេចក្តីសម្រេចដែល ខ្លួនបានសម្រេច គឺត្រូវផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយតាមដែលអាច និងទទួល

មតិយោបល់របស់សាធារណៈជន អំពីសេចក្តីសម្រេចនោះមកវិញ ទើបការអនុវត្តទទួលបានលទ្ធផលល្អ ។

ដោយក្រុមប្រឹក្សា ឃុំ សង្កាត់ ស្ថិតនៅកៀកប្រជាពលរដ្ឋមូលដ្ឋាន និង ដឹងច្បាស់អំពីសេចក្តីត្រូវការដូចនេះក្រុមប្រឹក្សា ឃុំ សង្កាត់ អាចធ្វើការដោះស្រាយ និង កែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការឆ្លើយតបទៅ និង តម្រូវការជាក់ស្តែងរបស់ពួកគាត់។

## ១.៥ ប្រវត្តិនៃការគ្រប់គ្រងវិមជ្ឈការ ឃុំ សង្កាត់

ឃុំ សង្កាត់ មិនដែលធ្លាប់មានអត្ថិភាពទេ នៅក្នុងប្រទេសកម្ពុជាតាំងពីមុនការមកដល់នៃ ពួកអាណានិគមនិយមបារាំង។ នាឆ្នាំ ១៨៧៥ ប្រព័ន្ធគ្រប់គ្រងរដ្ឋ នៅក្រោមការគ្រប់គ្រងបារាំងផង និង សៀមផង កត្តាទាំងអស់ខាងលើនេះហើយជាបទពិសោធន៍ និង ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីសង្គមខ្មែរនាអតីតកាលយកធ្វើជាមូលដ្ឋានសិក្សា ដើម្បីរៀបចំកែប្រែវាសនាអនាគតសង្គមជាតិខ្មែររបសយើង។

ព្រះរាជក្រឹត្យចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩០៨ បានបង្កើតនូវក្របខណ្ឌរដ្ឋបាលស៊ីវិលមួយដែលគេអាចនិយាយបានថាជាប្រភព នៃច្បាប់គ្រប់គ្រង " ឃុំ " របស់ប្រទេសកម្ពុជាដែលមានចែងអំពីនិយមន័យ " ឃុំ " ថា រួមមានការបញ្ចូលគ្រួសារជាច្រើន រួមគ្នាឲ្យបង្កើតបានជាភូមិ ហើយភូមិជាច្រើនរួមគ្នាបង្កើតបានជា ឃុំ មួយ។

នៅឆ្នាំ ១៩១៩ ដល់ ១៩៨៣ ដើម្បីឲ្យមានភាពកាន់តែជិតស្និទ្ធរវាងប្រជាជន និង រាជការ ក្នុងការបំពេញការងាររបស់ខ្លួនឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាព រដ្ឋាភិបាលអាណានិគមនិយមបារាំងបានផ្តួចផ្តើមឲ្យមានព្រះរាជក្រឹត្យចំនួនពីរទៀតគឺ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩១៩ ដែល រដ្ឋាភិបាលកណ្តាលបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុរបស់ខ្លួន ឲ្យដល់ឃុំជាអ្នកគ្រប់គ្រង និង ផ្តល់អំណាចឲ្យមេឃុំ ជាអ្នករៀបចំអភិវឌ្ឍមូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។ ហើយព្រះរាជក្រឹត្យមួយទៀតចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំង ផ្តល់ឲ្យមេឃុំ នូវអំណាចក្នុងការរៀបចំចាត់ចែងការងារយុត្តាធិការ ការងារគ្រប់គ្រងរដ្ឋបាល ឃុំ ការងារហិរញ្ញវត្ថុ ដោយមានកម្រិតអត្រាពន្ធ អាករឃុំ កំណត់តម្លៃសម្រាប់ការងាររដ្ឋបាល និង ធ្វើបុរេប្រទាន។ ហើយព្រះរាជក្រឹត្យនេះ ក៏នៅបានផ្តល់ឲ្យ ឃុំ បោះឆ្នោតរៀបចំនូវក្រុមជំនុំរបស់ខ្លួន ដែលកើតចេញពីការបោះឆ្នោត ហើយជ្រើសរើស មេឃុំ ម្នាក់ ដែលជាអ្នកទទួលខុសត្រូវ ចំពោះការអនុវត្តសេចក្តីសម្រេចរបស់ក្រុមជំនុំដែលជា នីតិបុគ្គល និងមានអាណត្តិ ៤ឆ្នាំ។ បន្ទាប់ពីការបោះឆ្នោតគេសង្កេតឃើញថា មានការអភិវឌ្ឍយ៉ាងច្រើន

និង ប្រជាពលរដ្ឋរស់នៅសមរម្យ ដោយសារមានការចុះពង្រឹងនៅតាមមូលដ្ឋានពី រដ្ឋបាលកណ្តាល។

ក្នុងឆ្នាំ ១៩៤៣ ដោយាសារប្រទេសមានសង្គ្រាមឈ្លានពាន ប្រព័ន្ធបោះឆ្នោតនៅឃុំ ត្រូវបានលុបចោលស្ទើរទាំងស្រុង ដោយដាក់ជំនួសការតែងតាំងមេឃុំ និង ជំទប់ ពីសំណាក់អភិបាលខេត្ត និង ដោយមានការយល់ព្រមពីរ៉េស៊ីដង់។ ព្រះរាជក្រម លេខ៤០នស ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ១៩៤៣ បានប្រកាស ឲ្យឃុំ ដែលមានចំនួនប្រជាជនច្រើនមិនឲ្យមានការបោះឆ្នោតទេ ចំណែកឯឃុំ ដែលមានប្រជាជនតិច គឺ អនុញ្ញាតិឲ្យមានការបោះឆ្នោតដដែល ប៉ុន្តែមិនត្រូវបានគេអនុវត្តទេ។ រហូតដល់ឆ្នាំ ១៩៤៨ ការបោះឆ្នោតជ្រើសរើសក្រុមជំនុំ ត្រូវបានផ្អាកទាំងស្រុង ។ ហើយនៅក្នុងឆ្នាំ ១៩៥៥ មានសារាចរណែនាំមួយឲ្យការបោះឆ្នោតមេឃុំឡើងវិញ តែវាមិនសូវមានប្រសិទ្ធភាពដូចពីមុនមកទេ។

ដោយយល់ឃើញ អំពីសារៈប្រយោជន៍នៃការបោះឆ្នោតជ្រើសរើសក្រុមជំនុំ ទើបនៅឆ្នាំ ១៩៥៩ មានព្រះរាជក្រមមួយទៀត លេខ៣៤០នស ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៥៩ បានតម្រូវឲ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ជានីតិបុគ្គលដូចនៅឆ្នាំ ១៩២៥ សម្រាប់រយៈពេល ០៤ ឆ្នាំ។ ហើយមេឃុំ និង ជំទប់ ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំដែលជាប់ឆ្នោត ដោយយកតាមសម្លេងភាគច្រើន។ រចនាសម្ព័ន្ធដែលមាននៅពេលនោះ គឺមានមេឃុំ ជំទប់ និង ស្មៀន គឺ ជាអ្នកដឹកនាំអនុវត្តផ្ទាល់( អង្គការប្រតិបត្តិឃុំ ) និង ក្រុមជំនុំជាអ្នកដឹកនាំអង្គការបញ្ញត្តិឃុំ ដោយមានមេឃុំ ជាប្រធាននៃក្រុមជំនុំ។ ហើយ ចៅហ្វាយ ខេត្ត គឺ ជាអ្នកចេញដីកាខេត្តប្រកាសសុពលភាព និង តែងតាំងមេឃុំ និង ក្រុមជំនុំតាមដីការបស់ខេត្ត។

តែមិនដល់រយៈពេលបីខែផង ព្រះរាជក្រមនេះត្រូវបានគេដាក់ព្យួរទុកក្នុងរយៈពេលមិនកំណត់ បន្ទាប់ពីបានធ្វើប្រជាមតិនៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩ ។ ដូចនេះ មេឃុំ និង ជំទប់ មិនត្រូវបានបោះឆ្នោតទេ ហើយនៅតែមានការតែងតាំងពីអភិបាលខេត្ត ។ រហូតមកដល់ឆ្នាំ ១៩៦៩ តាមព្រះរាជក្រឹត្យលេខ៣៨៣/៦៩CE/ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ១៩៦៩ បានប្រកាសកែប្រែឲ្យឈប់ធ្វើការបោះឆ្នោតជ្រើសរើសក្រុមជំនុំ មេឃុំ និង ជំទប់។ ហើយមេឃុំ ជំទប់ ត្រូវបានតែងតាំងតាមរយៈដីកាខេត្តតាមសំណើរបស់អភិបាលស្រុក។ចាប់ពីពេលនោះមក ឃុំ លែងមានថវិកាផ្ទាល់ខ្លួន និង គ្មានការបោះឆ្នោតទៀតហើយ។ បន្ទាប់ពីសមាជជាតិលើកទី ២០ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ១៩៦៥ គេបានស្នើសុំឲ្យប្តូរ ពាក្យ " ឃុំ " ទៅជា " សង្កាត់ " សម្រាប់ហៅនៅក្នុងទីក្រុង ហើយរក្សាពាក្យ " ឃុំ " សម្រាប់ការហៅនៅ " ខេត្ត " ដដែល។

ហើយនៅឆ្នាំ ១៩៩៦- ១៩៩៧ ក្នុងនីតិកាលទី១ នៃរដ្ឋសភា ក្រសួងមហាផ្ទៃដោយទទួលបាន ការណែនាំគោលនយោបាយពីរាជរដ្ឋាភិបាល ហើយបានសិក្សាស្រាវជ្រាវ រៀបចំតាក់តែងច្បាប់ និង លិខិតបទដ្ឋានគ្រប់គ្រង ឃុំ សង្កាត់ ឲ្យក្លាយជានីតិបុគ្គល។ សេចក្តីព្រាងច្បាប់នេះ ស្តីពីការគ្រប់ គ្រង ឃុំ សង្កាត់ និង សេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបាន រៀបចំ រួចហើយ ប៉ុន្តែដោយសារស្ថានភាពនយោបាយនៅកម្ពុជាមានបញ្ហាបន្តិចបន្តួចទើបមិនអាច យកមក ពិភាក្សានៅក្នុងគណៈរដ្ឋមន្ត្រីបាន។

ក្រោយពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី២ រួចរាល់ហើយ ក្រសួង មហាផ្ទៃបានបន្តលើកយកសេចក្តីព្រាងច្បាប់ទាំងពីរខាងលើ ធ្វើសារជាថ្មីម្តងទៀត ដោយផ្អែកសភាព ការណ៍ជាក់ស្តែង នៃនិន្នាការវិវត្តន៍នៃសង្គមជាតិ និង ភាពចាំបាច់ សម្រាប់លប់បំបាត់ភាពអសកម្មនៅ មូលដ្ឋាន ការប្រឆាំងអំពើពុករលួយ កាត់បន្ថយភាពក្រីក្រ និង ចង់ឲ្យមានការចូលរួមយ៉ាងសកម្មពី សំណាក់ប្រជាពលនៅក្នុងដំណើរការអភិវឌ្ឍសង្គមជាតិ ។ ហើយសេចក្តីព្រាងច្បាប់ទាំង ២ ខាងលើ ត្រូវបានដាក់ជូនរដ្ឋសភាពិនិត្យ និង អនុម័ត នៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០០១ ។ ហើយការគ្រប់គ្រង ឃុំ សង្កាត់ តាមបែបវិមជ្ឈការ នៅកម្ពុជាក៏ចាប់ផ្តើមអនុវត្តឡើងវិញ សារជាថ្មីទៀតចាប់ពីពេលនោះ រហូតដល់ពេល បច្ចុប្បន្ន។

សរុបមកជាប្រវត្តិនៃការអនុវត្តរដ្ឋបាល ឃុំ សង្កាត់ នៃប្រទេសកម្ពុជា គេសង្កេតឃើញមានការ កែប្រែជាញឹកញាប់ ក្នុងគោលបំណងធ្វើយ៉ាងណា ឲ្យការគ្រប់គ្រងនៅតាមមូលដ្ឋានឆ្លើយតបទៅនិង តម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងនោះគេសង្កេតឃើញថា ចាប់តាំងពីឆ្នាំ ១៨៨៩ ដល់ឆ្នាំ ១៩៥៣ មាន ការកែប្រែធំៗចំនួន៧ គឺ នៅក្នុងឆ្នាំ ១៨៨៩ គឺបារាំងបានកែសម្រួលរដ្ឋបាលទាំងស្រុង ហើយ ឆ្នាំ ១៩០១ បារាំងបានបញ្ចូលគោលការណ៍ជ្រើសរើស មេឃុំ និង ក្រុមជំនុំ។ បន្ទាប់នៅឆ្នាំ ១៩០២ បារាំង ឲ្យប្រាក់ កំរៃ ដល់មេឃុំ និង ក្រុមជំនុំ ហើយឆ្នាំ ១៩១៩ បារាំងបានប្រគល់ប្រភពធនធានហិរញ្ញវត្ថុ ឲ្យ ដល់ឃុំ ជាអ្នកគ្រប់គ្រង និង ផ្តល់អំណាចឲ្យមេឃុំ ជាអ្នករៀបចំអភិវឌ្ឍមូលដ្ឋានឃុំរបស់ខ្លួនផ្ទាល់។ នៅ ក្នុងឆ្នាំ១៩២៥ រដ្ឋាភិបាលអាណានិគមនិយមបារាំង បានផ្តល់ឲ្យមេឃុំ នូវអំណាចក្នុងការរៀបចំ ចាត់ចែងការងារ យុត្តាធិការការងារគ្រប់គ្រងរដ្ឋបាលឃុំ ការងារហិរញ្ញវត្ថុ ដើម្បីឲ្យការងារកាន់តែមាន ប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន។

## ១.៦ រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

ដោយសារតែមានកិច្ចព្រមព្រៀងសន្តិភាពនាឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានរៀបចំចងក្រងឡើងវិញនៃប្រព័ន្ធរដ្ឋបាលមិនមែនកុំមុយនិស្តរបស់ខ្លួនស្របទៅតាមឆន្ទៈមោះមុតរបស់ អ្នកនយោបាយខ្មែរ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ នៅកម្ពុជាដែលឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រជាតិស្តីពីវិមជ្ឈការ ។ ហើយច្បាប់នេះ គឺ ជាក្របខណ្ឌ គតិយុត្តជាមូលដ្ឋានសម្រាប់អនុវត្ត ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់តាមបែបវិមជ្ឈការ។

នៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០២ អនុលោមតាមច្បាប់ស្តីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់ ប្រទេសកម្ពុជា បានរៀបចំការបោះឆ្នោតរបស់ខ្លួនតាមលក្ខណៈប្រជាធិបតេយ្យដោយធានាសេរីភាព ភាពត្រឹមត្រូវ និង យុត្តិធម៌ ក្នុងការបោះឆ្នោត ជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំ សង្កាត់។

### ១.៦.១ ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការតំណាងប្រពលរដ្ឋនៅក្នុងឃុំ សង្កាត់ របស់ខ្លួន និង ជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតក្រោមការប្រគល់អំណាចរបស់រដ្ឋ។[1] ក្នុងនាមតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាមានតួនាទី ធំធេងក្នុងការបម្រើកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ផាសុកភាព និង សុខមាលភាពសេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន-ល- ក្នុងក្របខណ្ឌនយោបាយវិមជ្ឈការ។ ហើយតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺមានសមាជិកពី ៥ ទៅ ១១ នាក់ ដោយយោងទៅតាមលក្ខខណ្ឌភូមិសាស្ត្រនិងប្រជាសាស្ត្រ។ ក្រុមប្រឹក្សានេះត្រូវបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន[2] ស្របតាមនីតិវិធីដែលបានកំណត់ ហើយ ឃុំ សង្កាត់មានភារកិច្ចទទួលខុសត្រូវក្នុងការអភិវឌ្ឍឃុំ សង្កាត់ របស់ខ្លួន ដោយត្រូវមានប្រធាន ក្រុមប្រឹក្សា ជា មេឃុំ ចៅសង្កាត់។

[1] មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

[2] មាត្រា២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

### ១.៦.១.១ អាណត្តិ និង ការរំលាយ

ការអនុវត្តប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ឃុំ សង្កាត់ [3] មិនអាចនិងបំពេញការងារបានទេ ដោយសារមានមាត្រា១៦ដែលមិនអាចឲ្យក្រុមប្រឹក្សាបំពេញភារកិច្ចរបស់ខ្លួនឲ្យបានឯករាជ្យទាំងស្រុងបានលុះទេ។រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ តែគេមិនឃើញមានមាត្រាណាមួយ នៃច្បាប់នេះ ដែលបានពន្យល់ពីអ្វីទៅដែលហៅថា " រដ្ឋបាលឃុំ សង្កាត់ " ទេ។

បេក្ខជនដែលមានសិទ្ធិឈរឈ្មោះ ជាបេក្ខជន នៃក្រុមប្រឹក្សាឃុំ សង្កាត់[4] លុះត្រាមាន សញ្ជាតិខ្មែរពីកំណើត ចេះអាន និង សរសេរអក្សរខ្មែរ មានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតនៅមូលដ្ឋានដែលខ្លួនកំពុងឈរឈ្មោះបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោត។

ដើម្បីមានមូលដ្ឋានសម្រាប់ការរៀបចំ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួនឈ្មោះ និង ព្រំប្រទល់របស់ឃុំ សង្កាត់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យបាន៩ខែនៃការបរិច្ឆេទ នៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូង។[5] ហើយការបោះឆ្នោតនេះធ្វើតែមួយថ្ងៃប៉ុណ្ណោះ គឺ នៅថ្ងៃអាទិត្យ និង កំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នេះ ដូចជាមិនបានចែងឲ្យមានថាតើ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចប្តឹងទៅស្ថាប័នណា បើសិនជាខ្លួនកើតទុក្ខមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ សម្រេចរំលាយ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានបោះឆ្នោតដោយប្រជាពលរដ្ឋ។បើប្រៀបធៀបទៅ និង ច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់ នៅឆ្នាំ ១៩៥៩ សិទ្ធិនៃការរំលាយក្រុមជំនុំ ត្រូវបានគេផ្តល់ឲ្យមានការធ្វើប្រជាមតិ។ អាណត្តិ ក្រុមប្រឹក្សាឃុំ សង្កាត់បច្ចុប្បន្នមានរយៈពេល ៥ឆ្នាំ រីឯអាណត្តិរបស់ក្រុមប្រឹក្សាមានតែ ៤ឆ្នាំតែប៉ុណ្ណោះ។

### ១.៦.១.២ តួនាទី និង សមត្ថកិច្ច

ក្រុមប្រឹក្សា ឃុំ សង្កាត់ មានតួនាទី ជំរុញ និង គាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់

---

[3] មាត្រា៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

[4] មាត្រា៤៥ថ្មី ( មាត្រា៤៩ចាស់ ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

[5] មាត្រា៨៥ នៃជំពូកអន្តរប្បញ្ញត្តិ យោងតាមច្បាប់ស្តីពីការគ្រប់គ្រង ឃុំ សង្កាត់។

ធនធាននានា ដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាន ក្នុង ឃុំ សង្កាត់ របស់ខ្លួន បម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និង គោរពផលប្រយោជន៍ជាតិ ស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។ ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានផ្ទេរឲ្យនូវ តួនាទី មុខងារ និង អំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និង ការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

ក្រុមប្រឹក្សា ឃុំ សង្កាត់មានតួនាទី ២ គឺ តួនាទីបម្រើកិច្ចការមូលដ្ឋាន សម្រាប់បម្រើផលប្រយោជន៍ ឃុំ សង្កាត់ និង ប្រជាពលរដ្ឋនៅក្នុង ឃុំ សង្កាត់ របស់ខ្លួន និង តួនាទី ជាភ្នាក់តំណាងរដ្ឋក្រោមការ ចាត់តាំង ឬ ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

**តួនាទីបម្រើកិច្ចការមូលដ្ឋាន ( ជាអ្នកតំណាងឲ្យប្រជាជននៅមូលដ្ឋាន )**[6] គឺ ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និង របៀបរយសាធារណៈ។ ហើយរៀបចំចាត់ចែងសេវាសាធារណៈ និង មើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ។ លើសពីនេះទៅទៀតជំរុញយ៉ាងសកម្មនូវ កិច្ចអភិវឌ្ឍឃុំ សង្កាត់ និង សុខុមាលភាព។ ជាពិសេសប្រើប្រាស់ធនធានឲ្យបានត្រឹមត្រូវ ដើម្បីបម្រើឲ្យសេចក្តីត្រូវការរបស់ឃុំ សង្កាត់ និង ប្រជាជន។ ហើយ មានភារកិច្ចបម្រើកិច្ចការនៅមូលដ្ឋាន ដូចជាគ្រប់គ្រងសេវាសាធារណៈដើម្បីឆ្លើយតបទៅនិងសេចក្តីត្រូវការរបស់ប្រជាជននៅក្នុងមូលដ្ឋានឲ្យបានត្រឹមត្រូវ។ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋាន និង ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និង សម្របសម្រួលកិច្ចសហប្រតិបត្តិការល្អ ជាមួយអង្គការសង្គមស៊ីវិលផ្សេងៗ និង ជួយដោះស្រាយរាល់បាតុភូតនានា ដែលជាទំនាស់កើតមាន ឡើងក្នុងចំណោមប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន។

នៅក្នុងតួនាទីខាងលើនេះ ក្រុមប្រឹក្សាអាចធ្វើប្រតិភូកម្មអំណាច ទៅឲ្យមេឃុំ ចៅសង្កាត់ ជាអ្នកអនុវត្តផ្ទាល់បាន។ តែក្នុងករណីមានការដកមកវិញនូវអំណាចប្រតិកម្មនេះ គឺ មិនអាចធ្វើឲ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការទាំងឡាយ ដែលបានធ្វើរួចហើយនោះទេ។ ហើយការធ្វើបែបនេះ ដើម្បីធានា នូវ ប្រក្រតីភាពការងាររដ្ឋបាល ហើយមេឃុំ ចៅសង្កាត់ ក៏ត្រូវតែទទួលខុសត្រូវចំពោះមុខ ក្រុមប្រឹក្សា ឃុំ សង្កាត់ ផងដែរ។

**តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**[7] គឺ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវអនុវត្តតាមច្បាប់ ព្រះរាជក្រឹត្យ

---

[6] មាត្រា៦១ អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់។

[7] មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋាន នានា។ ហើយក្រុមប្រឹក្សាមានសិទ្ធិសម្រេចលើបញ្ហានានា ដូចជា អនុម័តលើគម្រោងផែនការអភិវឌ្ឍ ឃុំ សង្កាត់ និង អនុម័តលើគម្រោងថវិកា ឃុំ សង្កាត់។ លើសពីនេះទៅទៀតអនុម័តបទបញ្ជាផ្ទៃក្នុង និង ដីកា ឃុំ សង្កាត់ និង កិច្ចការផ្សេងទៀតៗដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រុមប្រឹក្សា ឃុំ សង្កាត់ អាចទទួលប្រតិភូកម្ម អំណាចពី ក្រសួង ស្ថាប័ននានា ដើម្បីអនុវត្តការងារក្នុងនាមរដ្ឋ។ ក្នុងករណីនេះ អាជ្ញាធរអាចធ្វើប្រតិភូកម្មអំណាចដល់ ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការ បង្កើនសមត្ថភាព និង ផ្គត់ផ្គងមធ្យោបាយ សម្ភារៈ ថវិកា សម្រាប់ការអនុវត្ត។ ឧទាហរណ៍ៈ ការចុះ ឈ្មោះអ្នកបោះឆ្នោតនៅក្នុង ឃុំ សង្កាត់ជាដើម។

ដូចនេះ ការធ្វើវិមជ្ឈការនៅ ឃុំ សង្កាត់នេះ គឺ ឃុំ សង្កាត់ មិនគ្រាន់តែមានតួនាទីបម្រើកិច្ចការមូលដ្ឋានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែ ឃុំ សង្កាត់ មានតួនាទីជាភ្នាក់ងារតំណាងរដ្ឋថែមទៀតផង។ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ នៅថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ២០០២ មក ទល់ពេលបច្ចុប្បន្ននេះ មានរយៈពេលជាច្រើនឆ្នាំណាស់មកហើយដែរ ពាក្យថាច្រកចេញចូលតែមួយ សម្រាប់រដ្ឋបាលឃុំ សង្កាត់ គឺ មិនទាន់មានការអនុវត្តនោះទេ។

ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង តួនាទី និង ភារកិច្ចទាំងអស់នោះ គឺ គ្រាន់តែមានចែងនៅក្នុងច្បាប់ប៉ុណ្ណោះ ពិតមែនថា ក្រុមប្រឹក្សា ឃុំ សង្កាត់បានធ្វើការងាររបស់ខ្លួនយ៉ាងច្រើន តែទាំងអស់នោះនៅមិនទាន់ធនល្មមទៅនិងស្ថានភាពជាក់ស្តែង ដែលមាននៅក្នុងមូលដ្ឋាននោះទេ។ ជាក់ស្តែងគេ អាចលើកយក ប្រធានបទមួយមកចោទជាបញ្ហាថា តើគ្រាន់តែការដោះស្រាយទំនាស់ដីធ្លីមាននៅក្នុងមូលដ្ឋាន ហើយអាជ្ញាធរបានដឹងយ៉ាងច្បាស់ ហេតុអ្វីបានជាពួកគេមិនអាចដោះស្រាយទៅបានអញ្ចឹង? តើអាជ្ញាធរមូលដ្ឋានពិតជាបម្រើដល់សេចក្តីសុខរបស់ប្រជាពលរដ្ឋបានទេ? តើប្រជាពលរដ្ឋអាចមានភាពកក់ក្តៅចំពោះអាជ្ញាធររបស់ខ្លួនបានដែរ ឬ ទេ?

ទំនាស់ដីធ្លី ត្រូវបានកើតឡើងជាបន្តបន្ទាប់នៅមូលដ្ឋាន ដែលបញ្ហាទាំងនេះធ្វើឲ្យប្រជាពលរដ្ឋមានកង្វល់ និង ពោលពេញទៅដោយការភ័យខ្លាច នៅពេលដែលមានបញ្ហាទំនាស់កើតឡើងចំពោះពួកគាត់ ។ ហើយវាជាភាពកំសោយមួយរបស់សមត្ថកិច្ចនៅតាមមូលដ្ឋាន ក្នុងការធានាឲ្យប្រជាពលរដ្ឋ រស់នៅដោយសុខដុមរម្យនាទេ។ ជាទូទៅ ប្រជាពលរដ្ឋដែលរស់នៅលើដីធ្លី គឺ តែងតែមានការដឹងលឺពីអាជ្ញាធរ នៅតាមមូលដ្ឋានរបស់ពួកគាត់ ប៉ុន្តែនៅពេលដែលមានបញ្ហាកើតឡើង ចំពោះរាស្ត្រប្រជា អាជ្ញាធរមានសមត្ថកិច្ចហាក់មិនសូវអើពើ និង ដោះស្រាយចំពោះបញ្ហានោះទេ គឺ ហាក់ដូចជាបង្ហាញ ថាពួកគាត់មិនបានដឹងលឺអ្វីទាល់តែសោះ។

### ១.៦.១.៣ ទំនាក់ទំនងក្នុងប្រទេស និង ក្រៅប្រទេស

មានការពាក់ព័ន្ធ និង អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា ៤២ " រាល់ទំនាក់ទំនងជាផ្លូវការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន អាជ្ញាធរភ្នាក់ងារនានារបស់ រាជរដ្ឋាភិបាល ព្រមទាំងអង្គការជាតិ និង អន្តរជាតិ ត្រូវប្រព្រឹត្តិទៅតាមរយៈក្រសួងមហាផ្ទៃ។នៅក្នុងការអនុវត្តជាក់ស្តែង ក្រសួងមហាផ្ទៃបានធ្វើទៅតាមរយៈអភិបាលស្រុក ខណ្ឌ ខេត្ត រាជធានី នេះ គេគិតថាជាការផ្ទុយទៅ និង គោលការណ៍វិមជ្ឈការ អំណាច ដែលបើសិនជាការណ៍នោះវាពាក់ព័ន្ធទៅ និង ឃុំ សង្កាត់ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើទំនាក់ទំនងជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ មេឃុំ ចៅសង្កាត់ អាចទំនាក់ទំនង ជាមួយភ្នាក់ងារនានាតាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្រសួងមហាផ្ទៃអាចនិងអន្តរាគមន៍ ឬ អាចត្រួតពិនិត្យក្នុងករណីដែល ក្រសួង ស្ថាប័នរបស់ រាជរដ្ឋាភិបាល អង្គការជាតិ និង អង្គការអន្តរជាតិនានាដែលបានធ្វើសេចក្តីសម្រេចណាមួយ ឬ ប្តឹងតវ៉ាចំពោះក្រុមប្រឹក្សាឃុំ សង្កាត់។[8] អភិបាលខេត្ត រាជធានី ដោយសំអាងទៅលើការយល់ឃើញរបស់អង្គភាពរដ្ឋបាល មូលដ្ឋានខេត្ត រាជធានី និង ដើម្បីទទួលបានប្រយោជន៍ផ្ទាល់ខ្លួនបានធ្វើសេចក្តីសម្រេចលប់ចោលដីកា ឃុំ សង្កាត់តែម្តង។ ប្រការនេះវាជាការរំលោភលើអំណាចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងករណីដែល សមត្ថកិច្ចរបស់មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រាជធានី អាចនៅ " មានកម្រិត " ។

ដូចនេះតើនីតិបុគ្គលនៃ ឃុំ សង្កាត់មានទំហំ និង វិសាលភាពអំណាចកម្រិតណា ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

### ១.៦.១.៤ ព្រំដែនអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចធ្វើសកម្មភាពមួយណាដែលផ្ទុយ និង គោលការណ៍ បទបញ្ញាដែលបានធ្វើឡើង ដូចជារដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ។ បើមាត្រាច្បាប់ខ្លះបានចែងឲ្យឃុំ សង្កាត់ ធ្វើកិច្ចការខ្លះជាប្រយោជន៍ដល់ការងារអភិវឌ្ឍ និង ការគ្រប់គ្រងឃុំ សង្កាត់ របស់ខ្លួនតាមស្ថានភាពដែលអំណោយផលដល់ប្រជាពលរដ្ឋ។

ក្រុមប្រឹក្សាឃុំ សង្កាត់ គ្មានអំណាចក្នុងវិស័យមួយចំនួនដូចជា ព្រៃឈើ ប្រៃសណីយ៍ ការពារ

[8] មាត្រា៤៨ អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់។

ជាតិ សន្តិសុខជាតិ រូបិយវត្ថុ នយោបាយការបរទេស និង គោលនយោបាយសារពើពន្ធ[9] ដែលវិស័យទាំងនោះត្រូវបានរដ្ឋរក្សាទុក។ ក្រុមប្រឹក្សា ឃុំ សង្កាត់ ជាអ្នកសម្រេច បញ្ឈប់ សមាជិកក្រុម ប្រឹក្សា ឃុំ សង្កាត់ ដោយការបោះឆ្នោតតាមសម្លេងភាគច្រើនដាច់ខាត នៃសមាជិករបស់ខ្លួនទាំងមូល។

ប៉ុន្តែមានការបញ្ឈប់យ៉ាងដូចម្តេច បើសិនសមាជិកក្រុមប្រឹក្សាម្នាក់ៗសុទ្ធតែមានសេរីភាពក្នុងការបញ្ចេញមតិ ក្នុងអង្គប្រជុំ ហើយគ្មានការចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬ ឃុំខ្លួន ដោយសារការសំដែងយោបល់ ឬ បញ្ចេញមតិក្នុងអង្គប្រជុំ ក្រុមប្រឹក្សា ឃុំ សង្កាត់ បានឡើយ។ ហើយនៅពេលដែលសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ សុទ្ធសឹងជាសមាជិកគណបក្សនយោបាយ តើអាចបញ្ឈប់សមាជិកណាម្នាក់បានដែរឬទេ? បើសិនជាគាត់ជាសមាជិកបក្សតែមួយរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែរ។

ក្រុមប្រឹក្សា ឃុំ សង្កាត់ មិនអាច និង ចុះកិច្ចព្រមព្រៀង ឬក៏ចាត់ចែងការងារណាមួយជាមួយក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ឬ ផ្នែកឯកជនណាមួយ ដោយគ្មានការយល់ព្រមណាមួយពីក្រសួងមហាផ្ទៃជាមុនបានឡើយ ហើយ ឃុំ សង្កាត់ គ្មានសិទ្ធិខ្ចីប្រាក់ទេ។ ជាពិសេស ក្រុមប្រឹក្សា ឃុំ សង្កាត់ អាចអនុវត្តអំណាចរបស់ខ្លួន នៅក្នុងដែនដីដែលបានកំណត់ដោយច្បាប់តែប៉ុណ្ណោះ។

### ១.៦.២ មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ជាប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការរៀបចំផែនការអភិវឌ្ឍ ឃុំ សង្កាត់របស់ខ្លួន។ ហើយក៏ជាអ្នកដឹកនាំបញ្ជាប្រតិបត្តិ ដោយរួមមានកិច្ចការរដ្ឋបាលឃុំ សង្កាត់ផងដែរ ។ ដោយសារគេមិនអាចញែកឲ្យដាច់រវាងអំណាចប្រតិបត្តិ និង អំណាចបញ្ញត្តិដែលមាននៅក្នុងថ្នាក់រដ្ឋបាលឃុំ សង្កាត់ វាធ្វើឲ្យមេឃុំ ចៅសង្កាត់ មានតួនាទី ជាប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវធ្វើជាអធិបតីនៃ កិច្ចប្រជុំ របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយត្រូវជំរុញឲ្យមានការប្រជុំយ៉ាងតិចម្តងក្នុងមួយខែ និង ជាអ្នកធានាការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។[10]

មេឃុំ ចៅសង្កាត់ គឺ ជាអ្នកប្រតិបត្តិតាមការប្រគល់អំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ និង ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាថែមទៀតផង។ ហើយ មេឃុំ

[9] មាត្រា៤៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

[10] មាត្រា១៣ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ចៅសង្កាត់ ក៏មានភារកិច្ចទទួលខុសត្រូវចំពោះម្ចាស់សន្លឹកឆ្នោត ជាពិសេសចំពោះគោលនយោបាយ បក្ស ដែល មេឃុំ ចៅសង្កាត់ ក៏មិនអាចល្មើសបានដែរ។ វាជាបញ្ហា រដ្ឋបាលឃុំ សង្កាត់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងប្រកាន់យកគឺ " បក្ស " ជាធំលើអ្វីៗទាំងអស់ក្នុងកិច្ចការអភិវឌ្ឍ និង ដឹកនាំឃុំ សង្កាត់ ដែលមានលំនាំដូចគ្នាចំពោះរបបនយោបាយមិនមែនសេរីនិយមគឺអ្វីៗ សុទ្ធតែត្រូវបាន បក្សជាអ្នកកំណត់។

មេឃុំ ចៅសង្កាត់ មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល់ និង ជួយកិច្ចការទាំងឡាយណាដែលចាំបាច់។[11] ហើយមេឃុំ ចៅសង្កាត់មានសិទ្ធិជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌសម្រាប់ផ្តល់យោបល់ចំពោះកិច្ចការទាំងឡាយណាដែលមេឃុំ ចៅសង្កាត់យល់ឃើញថា ជាកិច្ចការបច្ចេកទេស ហើយដែលខ្លួនមិនមានលទ្ធភាព និង ត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់។ ហេតុនេះមេឃុំ ចៅសង្កាត់មានសិទ្ធជ្រើសរើសគណៈកម្មាការនានា ដើម្បីស្រាវជ្រាវចំពោះកិច្ចការជំនាញ និង រាយការណ៍ឲ្យខ្លួនវិញ ហើយគណៈកម្មាធិការនេះអាចបញ្ឈប់ពេលណាក៏បានដែរ។

មេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនដីឃុំ សង្កាត់ ដែលខ្លួនគ្រប់គ្រង[12] ដែលមានភារកិច្ចដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យ លេខ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៣។ ក្នុងតួនាទីនេះមេឃុំ ចៅសង្កាត់មានអំណាច ខ្លាំង បំផុតក្នុងការកំណត់ថានរណាម្នាក់បានកើត ឬ រស់នៅក្នុងឃុំ សង្កាត់របស់ខ្លួន។ បើសិនជាមេឃុំ ចៅសង្កាត់យកអំណាចនេះទៅប្រើក្នុងន័យល្អវាជាការប្រសើរណាស់ ចំពោះអភិបាលកិច្ចនៅមូលដ្ឋានរបស់ខ្លួន តែផ្ទុយទៅវិញ បើមេឃុំ ចៅសង្កាត់អាចបង្កើតនូវបរិយាកាសពុករលួយ និងការគាបសង្កត់ទៅលើការធ្វើសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណៈឲ្យនរណាម្នាក់ និង បន្លំ សំបុត្រ ទាំង ៣ នេះ សម្រាប់ឲ្យនរណាម្នាក់ដែលមិនមែនជាជនជាតិខ្មែរពិតប្រាកដ ដូចនេះវា និង ធ្វើឲ្យសង្គមជាតិមានភាពច្របូកច្របល់។

បើយើងពិនិត្យមើលពីតួនាទីរបស់មេឃុំ ចៅសង្កាត់ ដូចជាមានអំណាចច្រើនពេកហើយ។ ដូចជា មេឃុំ ចៅសង្កាត់ អាចតែងតាំងគណៈកម្មាការណាមួយសម្រាប់ឲ្យធ្វើកិច្ចការដែលខ្លួនយល់ ថាចាំបាច់ និង ការទទួលខុសត្រូវជ្រើសរើសមេភូមិជាដើម ដែលគេមើលទៅហាក់បីដូចមិនមែន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ទេ គឺជាការបោះឆ្នោតជ្រើសរើស មេឃុំ ចៅសង្កាត់ ទៅវិញ។

[11] មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

[12] មាត្រា៨ នៃអនុក្រឹត្យលេខ ១០៣អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន។

តាមការអនុវត្តជាក់ស្តែង តើមេឃុំ ចៅសង្កាត់ អាចបង្កើតគណៈកម្មាធិការតាមការចាំបាច់របស់ខ្លួនបាន ដែរឬទេ?

តាមពិតមាត្រានេះគ្រាន់តែមានក្នុងក្រដាសច្បាប់ទេ។ ដូចករណីក្នុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិរបស់ខ្លួនមួយចំនួនដូចជា គណៈកម្មាការសេដ្ឋកិច្ច គណៈកម្មាធិការហិរញ្ញវត្ថុ គណៈកម្មាធិការរដ្ឋបាល គណៈកម្មាធិការសង្គមកិច្ច គណៈកម្មាធិការសេវាសេធារណៈ និង គណៈកម្មាធិការសណ្តាប់ធ្នាប់សាធារណៈ ហើយមានចែងអំពីតួនាទី និង ភារកិច្ច តាមដីកាសង្កាត់ លេខ០០១/០២ ដ.ក ហើយពេលនោះមានការចេញប្រកាសបដិសេដ ដោយក្រសួងមហាផ្ទៃ លេខ ២៤៤៨ប្រ.ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០០២ ដោយគ្រាន់តែលើកឡើងនូវមូលហេតុ៣យ៉ាងរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន គឺ (១) មិនស្របច្បាប់នីតិវិធីដែលបានកំណត់, (២) ការកំណត់សមាសភាពគណៈកម្មាធិការនីមួយៗពុំបានសម្រេចដោយក្រុមប្រឹក្សាសង្កាត់ (៣) ការកំណត់ អំពីភារកិច្ចរបស់គណៈកម្មាធិការមួយចំនួនដែលច្បាប់ពុំទាន់ចេញ។

### ១.៦.៣ ជំទប់ទី១-ទី២ ឬ ចៅសង្កាត់ទី១-ទី២

ជំទប់ ឬ ចៅសង្កាត់រងជាជំនួយការមេឃុំ ចៅសង្កាត់ មានភារកិច្ចផ្សេងក្រៅពីបទបញ្ញត្តិអាស្រ័យដោយមេឃុំ សង្កាត់ប្រគល់ឲ្យ។ ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ ទទួលជួយ មេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយមេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមទៀតបានដល់ជំទប់ទី១ ចៅសង្កាត់រងទី១ ។ ជាពិសេស ជំទប់ទី១ ចៅសង្កាត់រងទី១ អាចបំពេញការងារជាមេឃុំ ចៅសង្កាត់ ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន។ ហើយជំទប់ទី២ ចៅសង្កាត់រងទី២ ទទួលជួយមេឃុំ ចៅសង្កាត់ លើកិច្ចការផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និង សណ្តាប់ធ្នាប់សាធារណៈ ។[13] ហើយអាចបំពេញការងារជាមេឃុំ ចៅសង្កាត់ ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និង ជំទប់ទី១ ចៅសង្កាត់រងទី១ អវត្តមាន។

### ១.៦.៤ គណៈកម្មាធិការ

គណៈកម្មាធិការនេះមានសមាជិក ៣នាក់ មានភារកិច្ចផ្តល់យោបល់ និង ជួយកិច្ចការងារជាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចជាការកសាងផែនការ និង ថវិកា។ ហើយត្រូវរាយការណ៍អំពី

[13] មាត្រា២៦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ការវិវឌ្ឍការងារប្រចាំ ខែរបស់ខ្លួន និង ផ្តល់វិធានការត្រូវអនុវត្ត ដែលពាក់ព័ន្ធទៅនិងការងារ។ គណៈកម្មាធិការនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យធ្វើជាប្រធានក៏បាន ឬ ក៏អាចយកប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យធ្វើជាប្រធានក៏បាន។

### ១.៦.៥ ស្មៀនឃុំ សង្កាត់

ស្មៀនឃុំ សង្កាត់ គឺ ជាមន្ត្រីស្ថិតនៅក្នុងក្របខណ្ឌលេខាធិការនៃក្រសួងមហាផ្ទៃ ដែលតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[14] តាមរយៈការប្រលង ជ្រើសរើសពីមន្ត្រីរាជការ សិស្ស និស្សិត មានភារកិច្ចជួយកិច្ចការឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ អាចនិងត្រូវផ្លាស់ប្តូរក្នុងករណី បើមានសំណើរពីមេឃុំ ចៅសង្កាត់ អនុលោមតាមការសម្រេចពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ តាមសម្លេងភាគច្រើនដាច់ខាត។ ហើយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលចែងថា ស្មៀន គឺ ជាអ្នកធានានិរន្តភាពនៃកិច្ចការរដ្ឋបាល ហើយតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ដូចនេះនៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ មួយចំនួនធំ ដែលមិនស្ថិតនៅក្នុង គណបក្សដូចគ្នា វានិងនាំឲ្យមានការលំបាកក្នុងការសហការពីស្មៀន និង មេឃុំ ចៅសង្កាត់ ដែលមាននិន្នាការនយោបាយខុសគ្នា។

ដូចនេះបើសិនជាស្មៀន ឃុំ សង្កាត់ មិនព្រមស្តាប់តាមបញ្ជា របស់មេឃុំ ចៅសង្កាត់ ដែលមាននិន្នាការនយោបាយខុសគ្នា តើមេឃុំ ចៅសង្កាត់មាន វិធានការបែបណា សម្រាប់គ្រប់គ្រងស្ថានភាព និង ធានាឲ្យការងារមានប្រសិទ្ធភាព?

យោងតាមមាត្រា ២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានទុកឲ្យមេឃុំ ចៅសង្កាត់ អាចមានសិទ្ធិដកស្មៀន បានគ្រប់ពេលវេលា ។ ហើយមាត្រា ២៩នៃច្បាប់នេះ ក៏បានផ្តល់ ការអនុញ្ញាតឲ្យមេឃុំ ចៅសង្កាត់ ជ្រើសរើសបុគ្គលិករដ្ឋបាល ផ្សេងទៀត ក្រៅពីស្មៀនបាន តាម ការសម្រេចរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ដើម្បីឲ្យគ្រប់គ្រងការងារមួយចំនួន ដូចជាការងារខាងច្បាប់ ខាងបច្ចេកទេស ថវិកា ជាដើម ហើយបុគ្គលទាំងនេះមិនស្ថិតក្រោមការបង្គាប់បញ្ជារបស់ស្មៀនឡើយ គឺស្ថិតក្រោមការបង្គាប់បញ្ជារបស់មេឃុំ ចៅសង្កាត់ និង ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ដើម្បីធានាឲ្យកិច្ចការនៅក្នុងឃុំ សង្កាត់ របស់ខ្លួនទទួលបាននូវប្រសិទ្ធភាព និង មានការអភិវឌ្ឍន៍។

[14] មាត្រា២៨ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ហើយនៅក្នុងការអនុវត្តជាក់ស្តែង បើស្មៀនឃុំ សង្កាត់មានប្រភពពីគណបក្សដូចគ្នា គឺ ក្រុមប្រឹក្សា ឃុំ សង្កាត់មិនអាចធ្វើទៅរួចទេ និង មានឧបសគ្គជាច្រើនក្នុងការដកសិទ្ធិពីស្មៀន ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប៉ុន្តែអាចធ្វើទៅរួចប្រសិនជាមានការគាំទ្រពីបណ្តាញ ទំនាក់ទំនងជាមួយ អភិបាល ស្រុក ខណ្ឌ ខេត្ត ក្រុង ដែលមនុស្ស នៅក្នុងបក្សតែមួយ យល់ព្រម ដោយឆ្លងតាមការពិនិត្យ ពិចារណាឲ្យមានភាពសមហេតុផលក្នុងផ្លូវនយោបាយ ឬ ភាពយកចំណេញ ខាងនយោបាយដែលស្មៀននោះមានការបម្រើយ៉ាងស្មោះត្រង់ ឬ ក៏សកម្មភាពរបស់ស្មៀន ធ្វើឲ្យប៉ះពាល់ដល់ ប្រជាប្រិយភាពរបស់បក្ស និង មិនស្មោះត្រង់ចំពោះក្រុមគណបក្សនយោបាយរបស់ខ្លួន។ ឧទាហរណ៍ៈ ស្មៀន ឃុំ សង្កាត់បានកំណត់សេវារដ្ឋបាល ក្នុងតម្លៃខ្ពស់ដើម្បីជាប្រយោជន៍ដល់ ខ្លួនដោយសំអាងថាថ្នាក់លើជាអ្នកកំណត់មកអញ្ចឹង ដែលជាគណបក្សបក្សដឹកនាំប្រទេសជាតិ ដូចនេះវានិងអាចប៉ះពាល់ដល់ការបោះឆ្នោតអាណត្តិក្រោយរបស់បក្ស ដូចនេះ ស្មៀនរូបនេះប្រាកដជាត្រូវទំលាក់ជាមិនខាន។

សព្វថ្ងៃរដ្ឋបាលនៃប្រទេសកម្ពុជាបានកំពុងធ្វើនយោបាយភាវូបនីយកម្ម តាំងពីថ្នាក់ភូមិ រហូតដល់រចនាសម្ព័ន្ធថ្នាក់កំពូល ដូចជារដ្ឋមន្ត្រី អភិបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ ជ្រើសរើសមនុស្សរបស់បក្ស។

ដូចនេះសម្រាប់អ្នកធ្វើការរាជការសុទ្ធសាធ ដែលមានចំនេះដឹង និង សមត្ថភាព ប៉ុន្តែគ្មានខ្សែ និង បក្សពួក ពិតជាមិនអាចមាននូវឱកាសនិងបានឡើងកាន់តំណែង និង ការងារក្នុងតួនាទីជាថ្នាក់ដឹកនាំណាស់ សូម្បីថ្នាក់ការិយាល័យ និង នាយកដ្ឋាន។ នេះហើយជាបញ្ហានៃការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅកម្ពុជា ដែលត្រូវតែធ្វើការកែទម្រង់ក្នុងទស្សនទានដើម្បីប្រយោជន៍ជាតិ។ តើដល់ពេលណា អាណត្តិណា ដែលគេអាចរៀបចំការគ្រប់គ្រង រដ្ឋបាលឲ្យមានតម្លាភាព និង កាត់បន្ថយនូវប្រភេទ មនុស្សដែលចូលចិត្តឡេមឡើមអែបអប ដែលគ្មានចំណេះដឹង និង សមត្ថភាព។

### ១.៦.៦ មេភូមិ

តាមសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ លេខ០០៤ សណន ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០០៦ ដែលយោងទៅលើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់ គឺ បានកំណត់ច្បាស់លាស់អំពីលក្ខខណ្ឌ នៃការបាត់តំណែង របស់មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ។ លក្ខខណ្ឌទាំងនោះរួមមានសមីខ្លួនមរណៈភាព សាមីខ្លួនសុំលាឈប់ពីតំណែងជាលាយលក្ខណ៍អក្សរ សាមីខ្លួនបាត់កាយសម្បទាវិជ្ជាជីវៈ

សាមីុ ខ្លួនត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោត ឃុំ សង្កាត់ សាមីុខ្លួនត្រូវផ្តន្ទាទោស សាមីុខ្លួនផ្លាស់ទៅនៅភូមិ ផ្សេង និង សាមីុខ្លួនមានកំហុសក្នុងការងារត្រូវបញ្ឈប់ដោយក្រុមប្រឹក្សា ឃុំ សង្កាត់របស់ខ្លួន។

មានមូលហេតុមួយចំនួននៃការបញ្ឈប់មុខតំណែងមេភូមិ អនុប្រធានភូមិ និង សមាជិកភូមិមានដូចខាងក្រោមៈ

- ករណី មេភូមិ អនុប្រធានភូមិ និង សមាជិកភូមិណាមួយដែលប្រព្រឹត្តខុសឆ្គងក្នុងការងារ មេឃុំ ចៅសង្កាត់សាមីុ ត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរឲ្យកែចំណុចខុសឆ្គង និង រាយការណ៍ជូនកិច្ចប្រជុំបន្ទាន់របស់ក្រុមប្រឹក្សា ឃុំ សង្កាត់។
- នៅក្នុងករណីដែលទទួលការណែនាំហើយ សាមីុខ្លួននៅតែប្រព្រឹត្តខុសឆ្គង មេឃុំ ចៅសង្កាត់ ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សា ហើយក្រុមប្រឹក្សា អញ្ជើញសាមីុខ្លួនមកទទួលការណែនាំ ដោយមានការចុះក្នុងកំណត់ហេតុនៃកិច្ចប្រជុំ។
- ក្រោយពីទទួលការណែនាំហើយសាមីុខ្លួនមិនរាលចាល មេឃុំ ចៅសង្កាត់ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និង សុំឲ្យក្រុមប្រឹក្សាសម្រេចបញ្ឈប់ជននោះពីមុខតំណែងតាមសម្លេងលើសពីពាក់កណ្តាល នៃក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល។
- ករណីមេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ បាត់បង់ពីមុខតំណែងតាមករណីណាមួយ ខាងលើ ក្រុមប្រឹក្សាត្រូវធ្វើការជ្រើសរើសបេក្ខជនសម្រាប់កន្លែងដែលទំនេរ ឲ្យក្រុមប្រឹក្សា ពិនិត្យ និង អនុម័តក្នុងរយៈពេល៧ ថ្ងៃយ៉ាងយូរ។

ដោយយោងទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា ៣០ និង មាត្រា៣១ បាន ចែងថាក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំជ្រើសរើសឲ្យមានមេភូមិ ហើយមេភូមិត្រូវរៀបចំឲ្យមានអនុប្រធានភូមិ និង សមាជិកភូមិ១រូបជាជំនួយការ។ ដូចនេះមេភូមិគ្រាន់តែជាជំនួយការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គ្មានការកំណត់អាណត្តិទេ ហើយមេភូមិ អនុប្រធានភូមិ និង សមាជិកភូមិ មិនបានបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនោះទេ។ តើដំណើរការអនុវត្ត និង និតិវិធី នៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មានការប្រព្រឹត្តិយ៉ាងដូចម្តេច ?

# ជំពូកទី ២

# ដំណើរការអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ២.១ លិខិតរដ្ឋបាល ឃុំ សង្កាត់

លិខិតរដ្ឋបាលឃុំ សង្កាត់ ដែលប្រើប្រាស់ជាផ្លូវការ រួមមាន ដីកា សេចក្តីសម្រេច លិខិតស្នើ សេចក្តីជូនដំណឹង លិខិតអញ្ជើញ លិខិតបេសកកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និង ដីកាអម ដែលមានបង្ហាញដូចខាងក្រោមៈ

**ដីកា** ឃុំ សង្កាត់ ជាលិខិតបទដ្ឋានរដ្ឋបាលកំណត់នូវបទប្បញ្ញត្តិទាំងឡាយ ដែលរដ្ឋបាលឃុំ សង្កាត់បង្កើតឡើង ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ដោយស្មើភាពមិនរើស អើង និង សម្រាប់គ្រប់គ្រងកិច្ចការនានា ក្នុងក្របខណ្ឌតួនាទី មុខងារ និង អំណាចអនុវត្តក្នុងដែនដី របស់ខ្លួន។ ហើយ ដីកា ឃុំ សង្កាត់មិនត្រូវផ្ទុយនិងច្បាប់ និង លិខិតបទដ្ឋាននានារបស់រដ្ឋឡើយ។ ជាពិសេសដីកា ឃុំ សង្កាត់ត្រូវចុះហត្ថលេខា ដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំ ក្រុមប្រឹក្សា ឃុំ សង្កាត់ ( ការប្រជុំសាមញ្ញ ឬ វិសាមញ្ញ ) ដែលមានចំនួនលើសពីពាក់កណ្តាល នៃ សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងមូល។

**សេចក្តីសម្រេចឃុំ សង្កាត់** គឺ ជាលិខិតបទដ្ឋានរដ្ឋបាលបង្កើតឡើង ដើម្បីអនុវត្តដីការបស់ខ្លួន ឬ លិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំង ការរៀបចំ ឬ ការប្រគល់កិច្ចការនានា ក្នុងក្របខណ្ឌតួនាទី មុខងារ និង អំណាចអនុវត្តក្នុងរង្វង់ដែនដីរបស់ខ្លួន។ ហើយសេចក្តីសម្រេចនេះ មានលក្ខណៈប្រហាក់ប្រហែល និង ដីកាឃុំ សង្កាត់ដែរ ប៉ុន្តែ មានឋានានុក្រមទាបជាងដីកា និង ខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតនៅក្នុងឃុំ សង្កាត់។ លើសពីនេះទៅទៀត សេចក្តីសម្រេចឃុំ សង្កាត់មិនត្រូវផ្ទុយ និង ច្បាប់ និង លិខិតបទដ្ឋាននានារបស់រដ្ឋ និង ដីការបស់ខ្លួនឡើយ។ លើសពីនេះទៅទៀតសេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ តាមរយៈការសម្រេច របស់អង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងមូល។ ប៉ុន្តែក្នុងករណីប្រធានស័ក្ត និង បន្ទាន់បំផុតដែលមិនអាចកោះអញ្ជើញសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជុំបានទេ មេឃុំ ចៅសង្កាត់ អាចចេញសេចក្តីសម្រេចដើម្បីដោះស្រាយ ស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនោះ និង ត្រូវដាក់ជូនអង្គប្រជុំ ក្រុមប្រឹក្សាឃុំ សង្កាត់ នៅពេលបន្ទាប់ ដើម្បីពិនិត្យឡើងវិញនូវភាពត្រឹមត្រូវតាមច្បាប់។

**លិខិតស្នើ** គឺ ជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីបង្ហាញអំពីគោលបំណង និង មូលហេតុ នៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួន ថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ ឯកជន ក្រសួង ស្ថាប័ន អង្គការ ឬ សង្គមស៊ីវិល ដែលមានសិទ្ធិអំណាចសម្រេច ឬ ដោះស្រាយចំការស្នើនោះ។

**សេចក្ដីជូនដំណឹង** គឺ ជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការ សង្គមស៊ីវិល ដែលមានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬ ជាការឆ្លើយតបចំពោះសំណើរ ឬ ជាការជូនដំណឹងឲ្យសាធារណៈជនបានដឹង នូវព័ត៌មានទាំងឡាយដែល ឃុំ សង្កាត់ ត្រូវការផ្សព្វផ្សាយ។

**លិខិតអញ្ជើញ** គឺ ជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីធ្វើការអញ្ជើញបុគ្គល ឬ តំណាងក្រសួង ស្ថាប័ន អង្គការ សង្គមស៊ីវិល ឲ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនិង បុគ្គល ឬ អង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និង ឋានៈ( អ្នកដែលត្រូវអញ្ជើញ ) ទីកន្លែងប្រជុំ ឬ ប្រារព្វពិធី កម្មវិធី ឬរបៀបវិរៈប្រជុំ ( និងអាចមានឯកសារដែលពាក់ព័ន្ធនិងការប្រជុំ ភ្ជាប់ជាមួយ )។

**លិខិតបញ្ជាបេសកកម្ម** គឺ ជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីចាត់តាំងមន្ត្រី បុគ្គលិកឃុំ សង្កាត់ ចូលរួមក្នុងសកម្មភាពនានា នៅក្រៅឃុំ សង្កាត់ ។ លិខិតនេះមានភ្ជាប់ជាមួយនូវទិដ្ឋការធ្វើដំណើរ។ ហើយទិដ្ឋាការធ្វើដំណើរនេះគឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឲ្យអ្នកដែលមាន ភារកិច្ចទៅបំពេញបេសកកម្ម យកទៅចុះទិដ្ឋការនៅទីកន្លែង កាលបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និង ហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ច ដែលបានអនុញ្ញាតិ និង អង្គភាពដែលបានទទួល ដឹងឮអំពីការចេញដំណើរ និង ការមកដល់ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។ ហើយនៅពេលត្រលប់មកវិញត្រូវធ្វើរបាយការណ៍ ឬ រាយការណ៍ជូនមេឃុំ ចៅសង្កាត់ ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ឲ្យបានជ្រាបអំពីលទ្ធផល ឬ បញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម។

**របាយការណ៍** គឺ ជាសេចក្ដីរាយការណ៍អំពីសកម្មភាព ដំណើរការ និង លទ្ធផលការងាររបស់ឃុំ សង្កាត់ ឬ បុគ្គលិកណាមួយឬ មួយក្រុម ដែលរដ្ឋបាលបានចាត់តាំងឲ្យទៅបំពេញការងារ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ ឬ អង្គភាពពាក់ព័ន្ធ។ ហើយទម្រង់របាយការណ៍ត្រូវធ្វើជាប្រចាំខែ និង ប្រចាំឆ្នាំ របស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ដែលអនុវត្តតាមសេចក្ដីជូនដំណឹងលេខ ១៧១ ស.ជ.ណ ចុះថ្ងៃទី១៤ ខែ កញ្ញា ឆ្នាំ២០០៤ របស់ក្រសួងមហាផ្ទៃ។ លើសពីនេះទៅទៀតក្រៅពីទម្រង់របាយការណ៍ប្រចាំខែ

និង ប្រចាំឆ្នាំ មេឃុំ ចៅសង្កាត់ ក៏អាចបង្កើត និង ប្រើប្រាស់ទម្រង់របាយការណ៍ ផ្សេងៗទៀត សម្រាប់ប្រើប្រាស់ក្នុងឃុំ សង្កត់របស់ខ្លួន។

**កំណត់ហេតុ** គឺ ជាការកត់ត្រា ឬ ស្រង់យកមតិយោបល់ សេចក្តីសម្រេច និង ការឯកភាពលើសកម្មភាព ដែលត្រូវអនុវត្តពីគ្រប់សមាជិកអង្គប្រជុំ និង ការសម្រេចរបស់អង្គប្រជុំ ឬ ការកត់ត្រារាល់ហេតុការណ៍ណាមួយ ដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ។

**លិខិតផ្ទេរសិទ្ធិ** គឺ ជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយល័ក្ខណ៍អក្សរ ប្រគល់សិទ្ធិឲ្យជំទប់ ចៅសង្កាត់រង តាមឋានានុក្រមដើម្បីធ្វើជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងអំឡុងពេលដែលមេឃុំចៅសង្កាត់អវត្តមាន។

**ដីកាអម** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើង ផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែល ផ្ញើចេញទៅអង្គភាព ក្រសួង ស្ថាប័នណាមួយ ដោយមានកត់ត្រាឈ្មោះ និង ចំនួនលិខិត លើដីកាអមនោះ។ ហើយឃុំ សង្កាត់ប្រើដីកាអមនេះ ដើម្បីចៀសវាងការបាត់បង់ឯកសារ ដែលរដ្ឋបាល ឃុំសង្កាត់ផ្ញើចេញ។

## ២.២ កិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់

ដោយយោងទៅតាមច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រង់មាត្រា៖

មាត្រា២១ ចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ នីមួយៗត្រូវធ្វើការប្រជុំយ៉ាងតិចណាស់មួយដងក្នុងមួយខែ។ ហើយមាត្រា ២៣ មានចែងថា ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជាសាធារណៈ និង មានលក្ខណៈប្រជាធិបតេយ្យ។ ក្រៅពីកិច្ចប្រជុំ ជាសាធារណៈនេះ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំសម្ងាត់បានដែរ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មាន កិច្ចប្រជុំសាមញ្ញ ដែលជាកិច្ចប្រជុំរៀបចំឡើងយ៉ាងទៀតទាត់យ៉ាងហោចណាស់មួយដងក្នុងមួយខែ ហើយនិងកិច្ចប្រជុំពិសេស ដែលរៀបចំឡើងសម្រាប់ពិភាក្សា ការងារពិសេស ឬ ការងារបន្ទាន់។ ហើយកិច្ចប្រជុំ ទាំងពីរនេះអាចធ្វើជាសាធារណៈ ឬ ជាសម្ងាត់តាមករណីជាក់ស្តែង។ ហើយកិច្ចប្រជុំសម្ងាត់គេតែងតែរៀបចំឡើងសម្រាប់ពិភាក្សា លើបញ្ហា៖

- ការដាក់វិន័យ ឬ បញ្ឈប់សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់
- បញ្ហាសន្តិសុខ ក្នុងឃុំ សង្កាត់
- ការរៀបចំសំណុំរឿងដើម្បី តវ៉ា ឬ ការពារក្តីអ្វីមួយ
- ការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនិងកិត្តិយសបុគ្គល

### ២.២.១ ការត្រៀមរៀបចំកិច្ចប្រជុំ

មេឃុំ ចៅសង្កាត់ត្រូវធានាថា លិខិតអញ្ជើញត្រូវបានរៀបចំ និង ផ្ញើជូនអ្នកដែលត្រូវបានចូលរួមប្រជុំ គ្រប់គ្នាទាំងអស់ ឲ្យបានមុនពេលប្រជុំ។ ហើយលិខិតអញ្ជើញត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពី ពេលវេលា ទីកន្លែង និង បញ្ហាសំខាន់ដែលត្រូវពិភាក្សា ឬ ជម្រាបនៅពេលប្រជុំ។ លើសពីនេះទៅទៀតគ្រប់ការប្រជុំទាំងអស់ត្រូវមានរបៀបវារៈ ហើយត្រូវផ្ញើជូនអ្នកចូលរួមជាមុនសិនទើបប្រសើរ ដើម្បីឲ្យអ្នកចូលរួមទាំងអស់ត្រៀមនូវ សំណួរ និង ការបញ្ចេញមតិមួយចំនួនដែលមានប្រសិទ្ធ ភាពដល់ការប្រជុំ។ ហើយកិច្ចប្រជុំត្រូវមានរយៈពេលដែលសមមូលទៅ និង របៀបវារៈដែលបានកំណត់។

### ២.២.២ ការប្រព្រឹត្តិទៅនៃកិច្ចប្រជុំ

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និង អាចអនុវត្តមានបានលុះត្រាតែមានការអនុញ្ញាតជាមុន។ ហើយសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ មានសិទ្ធិបញ្ចេញមតិ និង និយាយដោយគ្មានការភ័យខ្លាច ការរំខាន ឬ ការបំភិតបំភ័យឡើយ។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីទី ត្រូវដឹកនាំរាល់កិច្ចប្រជុំ។ លើសពីនេះទៅទៀតស្មៀន ឃុំ សង្កាត់ បុគ្គលិកដទៃទៀតរបស់ឃុំ សង្កាត់ និង ប្រជាពលរដ្ឋមានសិទ្ធិចូលរួមប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ លើកលែងតែកិច្ចប្រជុំនោះ ត្រូវបានធ្វើឡើងដោយសម្ងាត់ ដូចនេះស្មៀនឃុំ សង្កាត់ និង ប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាត ឲ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង ការបោះឆ្នោតឡើយ។

កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រព្រឹត្តទៅដោយស្របច្បាប់ លុះត្រាតែមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួមប្រជុំ។ កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោមៈ

- បញ្ជាក់អះអាងថា កិច្ចប្រជុំប្រព្រឹត្តទៅដោយស្របច្បាប់
- ពិនិត្យ និង អនុម័តកំណត់ហេតុនៅក្នុងកិច្ចប្រជុំលើកដំមុន ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។

- ពិភាក្សាតាមរបៀបវារៈនីមួយៗ ដូចជាពិនិត្យឯកសារ និង លិខិតផ្សេងៗ ដែលបានដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និង សម្រេច។
- បញ្ហាផ្សេងៗទៀត

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាថា កិច្ចប្រជុំប្រព្រឹត្តទៅក្នុងលក្ខណៈប្រជាធិបតេយ្យ មានសណ្តាប់ធ្នាប់ និង គ្មានការរំខាន។ ហើយអ្នកចូលរួមទាំងអស់មានសិទ្ធិបញ្ចេញមតិ និង មតិរបស់ ពួកគាត់ត្រូវបានយកមកពិចារណា។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រកាន់ឥរិយាបថឲ្យបានដូចគ្នា ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ទោះបីជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់នោះ បានបញ្ចេញមតិផ្ទាល់ខ្លួនបែបណាក៏ដោយ។ ហើយធានាថាស្ត្រី និង បុរសមានឱកាសស្មើគ្នាក្នុងការបញ្ចេញមតិ និង មានការប្រាស្រ័យទាក់ទងគ្នាដោយច្បាស់លាស់ និង មានសមភាព។ជាពិសេសប្រជាពលរដ្ឋដែលបានចូលរួម នៅក្នុងការប្រជុំពិភាក្សាលើរបៀបវារៈ គួរតែមានពេលវេលាសម្រាប់ឲ្យពួកគាត់ចោទជាសំណួរនៅពេលដែលពួកគាត់នៅមានមន្ទិល។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រប់រូប មានសិទ្ធិបោះឆ្នោតនៅក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់។ ការបោះឆ្នោតត្រូវធ្វើដោយការលើកដៃ ហើយសម្លេងគាំទ្រ និង មិនគាំទ្រត្រូវបានប្រកាសឲ្យបានដឹងភ្លាម និង ត្រូវកត់ត្រាទុកនៅក្នុងកំណត់ហេតុ។ ស្មៀនឃុំ សង្កាត់ បុគ្គល និង អ្នកផ្សេងទៀតដែលចូលរួមប្រជុំមិនត្រូវបានអនុញ្ញាតិឲ្យបោះឆ្នោតនោះទេ។ ហើយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាចយកជាការបាន លុះត្រាតែមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ទាំងមូល។ ប៉ុន្តែក៏មានករណីផ្សេងទៀតការធ្វើសេចក្តីសម្រេចអាចអនុវត្តបាន លុះត្រាតែមានសម្លេងភាគច្រើនដាច់ នៃចំនួនសមាជិកដែលមានវត្តមាន។

ស្មៀនឃុំ សង្កាត់ ទទួលខុសត្រូវក្នុងការសរសេរកំណត់ហេតុប្រជុំ ដោយពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រប់រូប និង ទទួលបានកំណត់ហេតុ ដែលបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំម្នាក់មួយច្បាប់ នៅពេលប្រជុំលើកក្រោយ ហើយរាល់សេចក្តីសម្រេចទាំងអស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបិទផ្សាយនៅលើក្តារព័ត៌ឃុំ សង្កាត់ មិនឲ្យលើសពី៤៨ ម៉ោង បន្ទាប់ពីការប្រជុំ។

## ២.៣ ប្រភពចំណូល ឃុំ សង្កាត់

មាត្រា៧៣ ឃុំ សង្កាត់ មានធនធានហិរញ្ញវត្ថុ ថវិការ និង ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និង មាត្រា ៨២

ឃុំសង្កាត់ត្រូវបង្កើត ឲ្យមានប្រព័ន្ធគ្រប់គ្រង តាមដាន ត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខ្លួន។

### ២.៣.១ ចំណូលផ្ទាល់

ឃុំ សង្កាត់មានសិទ្ធិការប្រមូលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ នៅក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន។ ពន្ធខាងលើនេះរាប់បញ្ចូលពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និង ពន្ធលើការជួល។ ប្រភេទកំរិត និង របៀបនៃការប្រមូល ចំណូលផ្ទាល់នេះ និងត្រូវកំណត់ក្នុងច្បាប់ដោយឡែក។ បច្ចុប្បន្នឃុំ សង្កាត់មិនអាចអនុវត្តប្រមូល ចំណូលផ្ទាល់នេះបានឡើយ ដោយហេតុថាមិនទាន់មានច្បាប់ស្តីពីការប្រមូលចំណូលនេះ។

### ២.៣.២ ចំណូលពីមូលនិធិឃុំ សង្កាត់

រដ្ឋបង្កើតឲ្យមានមូលនិធិ ឃុំ សង្កាត់ ហើយមូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិ និង ប្រាក់ចំណូលផ្សេងៗទៅឲ្យថវិកាឃុំ សង្កាត់ ។[15] ហើយក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកប្រតិបត្តិមូលនិធិឃុំ សង្កាត់។

អ្វីទៅជាមូលនិធិឃុំ សង្កាត់ ? មូលនិធិឃុំ សង្កាត់ គឺ ជាកញ្ចប់ថវិកាមួយដែលទទួលបានមកពីការ វិភាជន៍ចំណូលជាក់លាក់របស់រដ្ឋ ពីថវិកា ប្រចាំឆ្នាំ និង អនុប្បទា ការខ្ចីពីក្នុង និង ក្រៅរបស់ប្រទេស ដើម្បីធ្វើវិភាជន៍ទៅឲ្យ ឃុំ សង្កាត់ ។ ហើយធនធានសរុបនៃមូលនិធិត្រូវបានបែងចែកជាពីរសមាសភាគ គឺ សមាសភាគរដ្ឋបាលទូទៅ មិនត្រូវច្រើនជាង ១/៣ នៃមូលនិធិសរុប និង សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន មិនត្រូវតិចជាង ២/៣ នៃធនធានមូលនិធិសរុបទេ ។[16] មូលនិធិនេះផ្អែកលើរូបមន្តមួយជាក់លាក់ គឺ ចំណែកស្មើៗ គ្នា ទៅតាមចំនួនប្រជាជន និង ភាពក្រីក្រ ដែលនៅក្នុងមូលដ្ឋានរបស់ខ្លួន។

### ២.៣.៣ ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ

ចំណូលមុខងារជាភ្នាក់ងារ គឺ ជាចំណូលដែលបានមកពីការបំពេញភារកិច្ចដោយឃុំ សង្កាត់ជំនួសមុខឲ្យក្រសួង ស្ថាប័ន ឬ អង្គការនានាទៅតាមការព្រមព្រៀងគ្នា។ បច្ចុប្បន្ន ឃុំ សង្កាត់ត្រូវបានអនុញ្ញាតិឲ្យប្រមូលចំណូលពីការបំពេញមុខងារជាភ្នាក់ងារក្នុងការចុះអត្រានុកូលដ្ឋាន ដូចជា ថ្លៃជាវ

[15] មាត្រា៧៧ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។

[16] មាត្រា១២ នៃអនុក្រឹត្យ លេខ១៦ អនក្រ.បក ស្តីពីមូលនិធិឃុំ សង្កាត់។

ក្រដាស អត្រានុកូលដ្ឋានតាមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០០២។ ប៉ុន្តែ ចំណូលនេះ ត្រូវបានកាត់ចូលទៅក្នុងកំរៃរដ្ឋបាល( យោងទៅតាមសៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាល រំលឹកឡើងវិញស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

ក្រៅពីចំណូលសំខាន់ទាំង៣ ខាងលើនេះឃុំ សង្កាត់មានចំណូលផ្សេងៗទៀតដូចជា មានចំណូលពីការចូលរួមចំណែកប្រជាពលរដ្ឋនៅមូលដ្ឋាន និង ចំណូលពីអង្គការមិនមែនរាជរដ្ឋាភិបាល និង កម្មវិធីនានា។

ឃុំ សង្កាត់ ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ ថវិការ និង ទ្រព្យសម្បត្តិទាំងនេះយ៉ាងហ្មត់ចត់ ដើម្បីធានាថា ការប្រើប្រាស់ធនធានរបស់ ឃុំ សង្កាត់ ប្រកបដោយតម្លាភាព សន្សំសំចៃ និង មានប្រសិទ្ធភាពខ្ពស់។

## ២.៤ ថវិកាឃុំ សង្កាត់

ថវិកា គឺ ជាលិខិតគតិយុត្តិ[17] ដែលក្រុមប្រឹក្សា ឃុំ សង្កាត់ មានសិទ្ធិពេញលេញក្នុងការគ្រោងចំណូល ចំណាយ និង អនុវត្តចំណូល ចំណាយតាមថវិកាគ្រោង។

គោលការណ៍ថវិកាសំខាន់ៗ ទាក់ទង និង ការរៀបចំគម្រោង ថវិកា ឃុំ សង្កាត់គម្រោងថវិកា ឃុំ សង្កាត់ ត្រូវរៀបចំ និង អនុម័តប្រចាំឆ្នាំ ( ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ នៃឆ្នាំថវិកា) ហើយត្រូវតែមានតុល្យភាពទៅ និង ផែនការចំណាយសរុប និង ការធានារ៉ាប់រងពេញលេញដោយផែនការចំណូលសរុប។ ជាពិសេស ថវិកា ឃុំ សង្កាត់ ត្រូវតែឆ្លុះបញ្ចាំងអំពីចំណាយជាអាទិភាព របស់ផែនការអភិវឌ្ឍឃុំ សង្កាត់។

លើសពីនេះទៅទៀតការរៀបចំអនុម័ត និង បញ្ជាក់ទទួលស្គាល់គម្រោងថវិកា មេឃុំ ចៅសង្កាត់ ត្រូវធានាថា ដំណើរការនៃការរៀបចំថវិកា មានការចូលរួមពីប្រជាពលរដ្ឋ នៅមូលដ្ឋានរបស់ខ្លួន។ ហើយគណៈកម្មាធិការកសាងផែនការ និង ថវិកាត្រូវជួយមេឃុំ ចៅសង្កាត់ ក្នុងការរៀបចំគម្រោងថវិកា ឃុំ សង្កាត់ បន្ទាប់ត្រូវដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និង អនុម័ត គម្រោងថវិកាឃុំ សង្កាត់ ហើតត្រូវបញ្ជូនគម្រោងថវិកាទៅឲ្យអភិបាលខេត្តក្រុងធ្វើការពិនិត្យ និង បញ្ជាក់ទទួលស្គាល់លើគម្រោងថវិកា។

[17] មាត្រា៣ អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់។

ថវិកា ឃុំ សង្កាត់អាច និង ត្រូវកែតម្រូវ ក្នុងឆ្នាំថវិកា ដោយមានការផ្លាស់ប្តូរសភាពការណ៍សេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលជះឥទ្ធិពល ដល់ការព្យាករណ៍ដំបូងនៃចំណូល និង ចំណាយ។ ហើយការកំណត់ ចំណូលផ្ទាល់របស់ឃុំ សង្កាត់ ត្រូវកំណត់ និង ប្រមូល តាមបទបញ្ញត្តិច្បាប់ដោយឡែក។ ខួបនៃការចំណាយ រួមមាន ការចំណាយ ការជម្រះបញ្ជី ការចេញអាណត្តិបើប្រាក់ និង ការទូទាត់ ដូចដែលបានបញ្ជាក់ក្នុងប្រកាសណែនាំ ស្តីពីនីតិវិធីចំណាយ និង លទ្ធកម្មរបស់ ឃុំ សង្កាត់។ របាយការណ៍អំពីលទ្ធផលនៃការអនុវត្តថវិកា ឃុំ សង្កាត់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្ត ថវិកាតាមប្រតិទិន និង នីតិវិធីដែលបានបញ្ជាក់ ក្នុងប្រកាសណែនាំស្តីពីប្រព័ន្ធទូទាត់ និង គណនេយ្យរបស់ ឃុំ សង្កាត់ ។ ការបិទបញ្ជីថវិកា នៅដំណាច់ឆ្នាំ ថវិកា ឃុំ សង្កាត់ ត្រូវបិទបញ្ជីថវិកា ហើយគណនេយ្យករ ឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍បិទបញ្ជី គណនេយ្យជូនមេឃុំ ចៅសង្កាត់ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និង អនុម័ត របាយការណ៍ បិទបញ្ជីគណនេយ្យ និង បញ្ជូនទៅអភិបាលខេត្តក្រុងពិនិត្យ និង បញ្ជាក់ទទួលស្គាល់លើសេចក្តីសម្រេចស្តីពីការបិទបញ្ជីថវិកា។

## ២.៥ ប្រព័ន្ធទូទាត់ គណនេយ្យ និង លទ្ធកម្ម ឃុំ សង្កាត់

### ២.៥.១ គោលការណ៍ទូទៅ

ឃុំ សង្កាត់ ត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារខេត្តក្រុង។ ហើយមេឃុំ ចៅសង្កាត់ ជាអាណាប័ក និង មានសិទ្ធិពេញលេញលើការប្រមូល ឬ សន្យាចំណាយ និង បញ្ជាចំណាយ ដោយផ្អែកលើថវិកាដែលបានអនុម័ត។[18] មេឃុំ ចៅសង្កាត់ អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅឲ្យជំទប់ ឬ ចៅសង្កាត់រង របស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះ ត្រូវធ្វើសកម្មភាពដោយស្ថិតក្នុងការទទួលខុសត្រូវ និង ត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់ ។ មេឃុំ ចៅសង្កាត់ និង អ្នកទទួលសិទ្ធិ ត្រូវតែតម្កល់គំរូហត្ថលេខាជាផ្លូវការនៅរតនាគារខេត្ត ក្រុង ហើយអ្នកទទួលសិទ្ធិ និង បុគ្គលិករដ្ឋបាលឃុំ សង្កាត់ ជាទូទៅមិនត្រូវបានអនុញ្ញាតិ ឲ្យកាន់កាប់មូលនិធិ ឬ ធ្វើការទូទាត់ចំណាយ លើកលែងតែក្នុងករណីទូទាត់បេឡាបុរេប្រទាន និង ចំណូលដែលប្រមូលបាន ដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀតសិទ្ធិបញ្ជាចំណាយ និង ការទូទាត់ មិនត្រូវប្រគល់ឲ្យមនុស្សតែម្នាក់បានឡើយ ហើយរតនាគារខេត្តក្រុងត្រូវបំពេញមុខងារ ជាគណនេយ្យករឃុំ សង្កាត់។

[18] មាត្រា២៧ អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់។

### ២.៥.២ ប្រព័ន្ធទូទាត់

ការទូទាត់ផ្ទាល់ គឺ គេទូទាត់តាមរយៈរតនាគារខេត្តក្រុង ហើយការទូទាត់តាមរយៈបេឡាបុរេប្រទានត្រូវប្រើសម្រាប់តែចំណាយចរន្ត( លើកលែងប្រាក់បៀវត្ស , ប្រាក់បំណាច់ ) និង ចំណាយវិនិយោគរដ្ឋបាល ។ ហើយការចំណាយមួយលើកៗ ចេញពីបេឡាបុរេប្រទាន ត្រូវមានចំនួនទឹកប្រាក់នៅក្រោមកំរិតមួយជាកំណត់ តាមនីតិវិធីបេឡាបុរេប្រទាន ។[19]

### ២.៥.៣ ប្រព័ន្ធគណនេយ្យ

គណនេយ្យករនៅរតនាគារខេត្តក្រុង មានភារកិច្ចអនុវត្តគណនេយ្យហិរញ្ញវត្ថុ ។ ហើយគណនេយ្យហិរញ្ញវត្ថុ គឺ ជាប្រព័ន្ធផ្អែកលើមូលដ្ឋានសាច់ប្រាក់។ ជាពិសេសចំណូលត្រូវកត់ត្រាក្នុងបញ្ជីគណនេយ្យ នៅពេលទទួលបានសាច់ប្រាក់និងចំណាយត្រូវកត់ក្នុងប្រព័ន្ធគណនេយ្យនៅពេលទូទាត់។

លើសពីនេះទៀត មេឃុំ ចៅសង្កាត់ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តគណនេយ្យថវិកា។ គណនេយ្យថវិកា គឺ ជាការតាមដាន និង រាយការណ៍អំពី ការអនុវត្តចំណាយថវិកាដែលបានអនុម័ត និង ការប្រមូលចំណូលថវិកាដែលបានអនុម័ត។

### ២.៥.៤ លទ្ធកម្មឃុំ សង្កាត់

លទ្ធកម្មឃុំ សង្កាត់ គឺ ជាការជួលអ្នកទទួលការ សម្រាប់ការងារសាងសង់ ឬ ជាការរកបាននូវទំនិញ និង សេវាពាក់ព័ន្ធ តាមរយៈវិធីសាស្ត្រលទ្ធកម្មសាធារណៈ។ ហើយគោលការណ៍លទ្ធកម្មដើម្បីៈ

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និង ការផ្តល់សេវាកម្មត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាព និង សន្សំសំចៃបំផុតប្រកបដោយប្រសិទ្ធភាព
- អ្នកទទួលការ និង អ្នកផ្គត់ផ្គង់ ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃ ក្រោមល័ក្ខខណ្ឌត្រឹមត្រូវ និង ស្មើភាព។
- លទ្ធផលនៃការដេញថ្លៃ ត្រូវផ្សព្វផ្សាយជាសាធារណៈ។

លើសពីនេះទៅទៀត មេឃុំ ចៅសង្កាត់ ជាប្រធាននៃគណៈកម្មការលទ្ធកម្ម ហើយសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ២ រូប ជាសមាជិក និង ស្មៀនឃុំសង្កាត់ ជាលេខាធិការ។ ហើយការដេញថ្លៃនេះ

[19] មាត្រា៣១ អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់។

គឺ ត្រូវមានការដេញថ្លៃដោយប្រកួតប្រជែងចំហរ ( ជាសាធារណៈ ) មានការស្ទង់តម្លៃក្នុងស្រុក និង មានការទិញផ្ទាល់ ឬ ការចុះកិច្ចសន្យាផ្ទាល់ (ការចរចាតម្លៃផ្ទាល់)។ ម៉្យាងវិញទៀត មេឃុំ ចៅសង្កាត់ មិនត្រូវធ្វើការទូទាត់ ឲ្យអ្នកទទួលការ ឬ អ្នកផ្គត់ផ្គង់ជាមុនទេ។ ការទូទាត់ត្រូវធ្វើឡើងតែនៅពេលណា ដែលសម្ភារៈ ឬ ទំនិញត្រូវបានប្រគល់ទទួលត្រឹមត្រូវនូវការងារសំណង់ និង ការងារសេវាកម្មត្រូវបាន បំពេញត្រឹមត្រូវ ទៅតាមល័ក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

## ២.៦ ប្រព័ន្ធកសាងផែនការឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និង អនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងគោល បំណងកំណត់នូវទស្សនៈវិស័យកម្មវិធី និង កិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។[20] ដើម្បីទទួលបាននូវ ប្រសិទ្ធភាព និង តម្លាភាព នៅក្នុងដំណើរការនោះ។

### ២.៦.១គោលការណ៍សំខាន់ៗការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគឃុំ សង្កាត់

គោលការណ៍នៃការកសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគនៅឃុំ សង្កាត់នេះមានដូចជាៈ

- ផែនការអភិវឌ្ឍឃុំ សង្កាត់ ត្រូវឲ្យស្រប និង ផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ។
- ផែនការអភិវឌ្ឍត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ណែនាំក្នុងការសម្រេចចិត្តក្នុងការងារ អភិវឌ្ឍ ឃុំ សង្កាត់ និង សម្រាប់កសាងកម្មវិធីវិនិយោគ និង ការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំសង្កាត់។
- ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវអនុម័ត ដោយក្រុមប្រឹក្សា ឃុំ សង្កាត់ នៅឆ្នាំទី១នៃអាណត្តិរបស់ ខ្លួន។
- ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវមានសុពលភាពរយៈពេល៥ឆ្នាំ ហើយត្រូវពិនិត្យឡើងវិញជារៀង រាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគ និង ថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។
- ផែនការអភិវឌ្ឍឃុំ សង្កាត់ រៀបចំជាលាយល័ក្ខអក្សរដោយមានផែនទី ស្ថិតិ និង ឯកសារពាក់ ព័ន្ធផ្សេងៗភ្ជាប់មកជាមួយផង។
- ផែនការអភិវឌ្ឍឃុំ សង្កាត់ ត្រូវធានាឲ្យមានការចូលរួមពីគ្រប់ភាគីនៃអ្នកពាក់ព័ន្ធ។
- ផែនការអភិវឌ្ឍឃុំ សង្កាត់ ដែលអនុម័តរួចជាឯកសារផ្លូវការ និង ត្រូវធ្វើការផ្សព្វផ្សាយ។

[20] មាត្រា៦០ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

### ២.៦.២ តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

#### ២.៦.២.១ មេឃុំ ចៅសង្កាត់

មេឃុំ ចៅសង្កាត់ទទួលខុសត្រូវ :

- ដឹកនាំការងារកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ ព្រមទាំងពិនិត្យ និង កែលម្អឡើងវិញជា រៀងរាល់ឆ្នាំ តាមរយៈការកសាងកម្មវិធីវិនិយោគ ឃុំ សង្កាត់។
- ដាក់ជូនសេចក្ដីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់ ទៅអភិបាលខេត្ត ក្រុងតាមរយៈ អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងដើម្បីពិនិត្យ និង ផ្ដល់យោបល់។
- ដាក់ជូនសេចក្ដីព្រាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុម័ត។
- រៀបចំ និង ដាក់ជូនសេចក្ដីព្រាងផែនការកសាងការងារសម្រាប់ កសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីអនុម័ត។

#### ២.៦.២.២ ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំសង្កាត់ ទទួលខុសត្រូវ

- អនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់ នៅឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន។
- អនុម័តរាល់ការកែតម្រូវ ផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងករណីចាំបាច់។
- អនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់ និង ការកែប្រែកម្មវិធីវិនិយោគឃុំ សង្កាត់
- ត្រួតពិនិត្យតាមដាន និង វាយតម្លៃ អំពីផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់។
- អនុម័តផែនការការងារសម្រាប់កសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់។

#### ២.៦.២.៣ គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ សង្កាត់ ( គ.ផ.ថ )

គ.ផ.ថ ទទួលខុសត្រូវ ៖

- ជួយមេឃុំ ចៅសង្កាត់ ក្នុងការកសាងផែនការអភិវឌ្ឍនិង កម្មវិធីវិនិយោគ ឃុំ សង្កាត់ និងរៀបចំថវិកាប្រចាំឆ្នាំ របស់ឃុំ សង្កាត់។

- អនុវត្តនីតិវិធីកសាងផែនការអភិវឌ្ឍ និង កម្មវីធីវិនិយោគឃុំ សង្កាត់ និង រៀបចំថវិការប្រចាំឆ្នាំរបស់ឃុំ សង្កាត់តាមអភិក្រម មានការចូលរួមគ្រប់អ្នកពាក់ព័ន្ធ។

**២.៦.២.៤ អភិបាលរាជធានី ខេត្ត**

- បង្កើតយន្តការគាំទ្រការកសាង និង អនុវត្តផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគ ឃុំ សង្កាត់ ។
- កៀរគរ និង ដឹកនាំចាត់ចែង សកម្មភាពរបស់មន្ទីរជំនាញខេត្ត ក្រុង និង អង្គភាពពាក់ព័ន្ធក្នុងការផ្តល់ការគាំទ្រ និង ណែនាំលើការងារបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់។
- ពិនិត្យ និង ផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់។

**២.៦.២.៥ អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត**

អង្គភាពមូលដ្ឋានខេត្ត ក្រុង ទទួលខុសត្រូវ :

- ជាខ្សែរយៈទំនាក់ទំនងទោលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយរដ្ឋបាលខេត្ត ក្រុង។
- ផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ និង អ្នកពាក់ព័ន្ធអំពីផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និង ការអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និង ការតាមដាន ការវាយតម្លៃអំពីផលប៉ះពាល់ នៃការអនុវត្តផែន ការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់។

**២.៦.២.៦ មន្ទីរផែនការរាជធានី ខេត្ត**

មន្ទីរផែនការខេត្ត ក្រុងទទួលខុសត្រូវ :

- គាំទ្របច្ចេកទេសកសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ដែលមានជាអាទ៍ការងារ ស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ សង្កាត់ការងារចងក្រងកម្រងព័ត៌មានស្ថានភាពឃុំ សង្កាត់ប្រចាំឆ្នាំការងារសម្របសម្រួលក្នុងការវិភាជន៍មូលនិធិនានា ការងាររៀបចំ និង សម្របសម្រួលក្នុងសិក្ខាសាលាសមាហរណ៍កម្មផែនការថ្នាក់ស្រុក ខណ្ឌ។
- សហការណ៍ជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងក្នុងការបណ្តុះបណ្តាលគ្រូបង្គោល ថ្នាក់

ខេត្ត ក្រុង ស្រុក ខណ្ឌ និង អ្នកពាក់ព័ន្ធអំពី បច្ចេកទេសកសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ។ បច្ចេកទេសតាមដាន និង វាយតម្លៃអំពីផលប៉ះពាល់ នៃការអនុវត្តផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ។

សហការផ្តល់ការគាំទ្របច្ចេកទេស អំពីផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគ ឃុំ សង្កាត់ និង ការតាមដាន និង វាយតម្លៃអំពីផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និង បុគ្គលិកសំខាន់ៗ របស់ឃុំ សង្កាត់តាមសំណើរពីអ្នកពាក់ព័ន្ធ។

### ២.៦.២.៧ មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្តនានា

មន្ទីរ និង អង្គភាពជំនាញខេត្ត ក្រុង នានាទទួលខុសត្រូវផ្តល់ជំនួយបច្ចេកទេសដែលពាក់ព័ន្ធ និង ជំនាញរបស់ខ្លួន ក្នុងការកសាងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ ក្នុងការរៀបចំ និង អនុវត្តគម្រោងនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់

### ២.៦.២.៨ អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលអាចចូលរួមក្នុងការរៀបចំ ផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគ ឃុំ សង្កាត់ ដោយទទួលខុសត្រូវ ចូលរួមជាតំណាងឲ្យផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និង អ្នកពាក់ព័ន្ធណាមួយជាក់លាក់ដូចជា ស្ត្រី កុមារ យុវជន ជនក្រីក្រ ជនជាតិដើមភាគតិច...។ចូលរួមចំណែកផ្តល់ចំណេះដឹង និង គំនិតផ្សេងៗក្នុងការរៀបចំ ផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគ ឃុំ សង្កាត់។

### ២.៦.៣ វដ្តនៃផែនការអភិវឌ្ឍឃុំ សង្កាត់




**ជំហានទី១ : សេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និង ថវិកា**

គណៈកម្មាធិការកសាងផែនការ និង ថវិកាត្រូវជួបប្រជុំនៅថ្នាក់ឃុំ សង្កាត់ ដើម្បីធ្វើការវិភាគទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាព ឃុំ សង្កាត់ និង ទិន្នន័យ ឬ ព័ត៌មាន ឬ ប្រើ ឧបករណ៍វិភាគផ្សេងៗ ក្នុងការកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និង ដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។

ហើយគណៈកម្មាធិការកសាងផែនការ និង ថវិកា ក៏ត្រូវរៀបចំប្រជុំ នៅតាមភូមិ ដើម្បីពិភាក្សា និង ធ្វើសុពលភាពទៅលើបញ្ហា មូលហេតុ និង ដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់ឃុំ សង្កាត់ និង ដើម្បីពិភាក្សា កំណត់បញ្ហា និង ដំណោះស្រាយនានាបន្ថែម។

គណៈកម្មាធិការកសាងផែនការ និង ថវិកា ជួបប្រជុំ នៅថ្នាក់ឃុំ សង្កាត់ ដើម្បីបូកសរុប បញ្ហា មូលហេតុ និង ដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា និង ពិភាក្សា កំណត់សេចក្តីត្រូវការនូវ

គោលដៅអភិវឌ្ឍ យុទ្ធសាស្ត្រអភិវឌ្ឍ សកម្មភាពជាអតិភាព ទំហំ គម្រោង ទីតាំងគម្រោង និង តម្លៃប៉ាន់ស្មានគម្រោង។

**ជំហានទី២ : កិច្ចប្រជុំ ពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ ឃុំ សង្កាត់**

កិច្ចប្រជុំ ពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍ ឃុំ សង្កាត់ ត្រូវបានរៀបចំឡើងដើម្បីប្រជុំពលរដ្ឋក្នុង ឃុំ សង្កាត់ និង អ្នកពាក់ព័ន្ធនានា ផ្តល់មតិ យោបល់ទៅលើសេចក្តីព្រាង ក្របខណ្ឌអភិវឌ្ឍ និង ថវិការបស់ឃុំ សង្កាត់ ។

**ជំហានទី៣ : សេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និង ថវិកា ត្រូវតែរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់ ហើយដាក់ជូនក្រុមប្រឹក្សា ឃុំ សង្កាត់ ដើម្បីពិនិត្យ និង ឯកភាព។

បន្ទាប់មកមេឃុំ ចៅសង្កាត់ ត្រូវផ្ញើសេចក្តីព្រាង ផែនការអភិវឌ្ឍឃុំ សង្កាត់ ជូនអភិបាលខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលខេត្ត ក្រុង ដើម្បីពិនិត្យ និង ផ្តល់យោបល់។

**ជំហានទី៤ : ការអនុម័តផែនការអភិវឌ្ឍឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និង ថវិកា និង ស្មៀនឃុំ សង្កាត់ ត្រូវធ្វើការពិនិត្យពិចារណា និង កែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍឃុំ សង្កាត់ ទៅតាមមតិយោបល់របស់អភិបាលខេត្ត ក្រុង។

ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យ និង អនុម័តសេចក្តីព្រាង ផែនការអភិវឌ្ឍ ឃុំ សង្កាត់ ហើយឯកសារ ផែនការអភិវឌ្ឍឃុំ សង្កាត់ ដែលបានអនុម័តត្រូវផ្សព្វផ្សាយជាសាធារណៈ និង ប្រើប្រាស់ជាមូលដ្ឋាន សម្រាប់កសាងកម្មវិធីវិនិយោគ ឃុំ សង្កាត់ប្រចាំឆ្នាំ។

**ជំហានទី៥ : ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍឃុំ សង្កាត់**

ការពិនិត្យ និង វាយតម្លៃទៅលើប្រសិទ្ធភាព នៃការអនុវត្តផែនការអភិវឌ្ឍ ឃុំ សង្កាត់ និង ដកស្រង់ បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រង ការអនុវត្ត និង ការរៀបចំផែនការពេលក្រោយទៀត គឺជារឿងដែលមានសារៈសំខាន់ណាស់សម្រាប់ឃុំ សង្កាត់របស់យើង។

## ២.៦.៤ វដ្តនៃកម្មវិធីវិនិយោគឃុំ សង្កាត់




### ជំហានទី១ : ការពិនិត្យបញ្ហា ឬ តម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ

គណៈកម្មាធិការកសាងផែនការ និង ថវិកា ត្រូវជួបប្រជុំ នៅថ្នាក់ឃុំ សង្កាត់ ដើម្បីពិភាក្សាពិនិត្យបញ្ហា ឬ តម្រូវការ មូលហេតុនៃបញ្ហា និង ដំណោះស្រាយឡើងវិញ ដោយធ្វើការផ្ទះបញ្ចាំងជាមួយ ទិន្នន័យ ឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពឃុំ សង្កាត់ និង ទិន្នន័យ ឬ ព័ត៌មានផ្សេងៗ ហើយកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និង ដំណោះស្រាយនានា សម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ បន្ទាប់មកគណៈកម្មាធិការកសាងផែនការ និង ថវិកា រៀបចំប្រជុំ នៅតាមភូមិ ដើម្បីពិភាក្សា និងធ្វើ សុពលភាព ទៅលើបញ្ហា មូលហេតុ និង ដំស្រាយទាំងឡាយដែលបានកំណត់ នៅថ្នាក់ ឃុំ សង្កាត់ និង ដើម្បីពិភាក្សាកំណត់ បញ្ហា ឬ ក៏តម្រូវការ និង ដំណោះស្រាយ នានាបន្ថែមតាមករណីជាក់ស្តែង។ លើសពីនេះទៅទៀតគណៈកម្មាធិការកសាងផែនការ និង ថវិកា ជួបប្រជុំ នៅថ្នាក់ឃុំ សង្កាត់ ដើម្បីបូកសរុបបញ្ហា មូលហេតុ និង ដំណោះស្រាយដែលបានមកពីបណ្តាភូមិនានានិងធ្វើការដោះស្រាយតាមតែអាចធ្វើទៅបាន។

**ជំហានទី ២ : ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និង ថវិកា ធ្វើការឆ្លុះបញ្ចាំងនូវជំហានទី១ ជាមួយ និង គម្រោងតាមបណ្តាឆ្នាំនីមួយៗ នៃផែនការអភិវឌ្ឍឃុំ សង្កាត់ ដើម្បីកំណត់គម្រោងវិនិយោគ ប្រចាំឆ្នាំ ដែលត្រូវយកទៅបង្ហាញ និង កៀរគរធនធាន នៅសិក្ខាសាលាសមាហរណ៍កម្មផែនការថ្នាក់ស្រុក ខណ្ឌ។

**ជំហានទី ៣ : សិក្ខាសាលាសមាហរណ៍កម្មផែនការ ថ្នាក់ស្រុក ខណ្ឌ**

សិក្ខាសាលាសមាហរណកម្មផែនការនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាសឲ្យមានការផ្សារភ្ជាប់កម្មវិធីវិនិយោគឃុំ សង្កាត់ជាមួយ និង ផែនការរបស់មន្ទីរ ជំនាញ អង្គភាពមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និង ដៃគូរអភិវឌ្ឍនានា។ ហើយនិងការកៀរគរ និង សម្របសម្រួលនានា ពីប្រភពផ្សេងៗ សម្រាប់គាំទ្រដល់គម្រោងវិនិយោគឃុំ សង្កាត់ និង ថែមទាំងជួយតម្រង់ទិស សកម្មភាព របស់មូលដ្ឋានឃុំ សង្កាត់ ឲ្យស្របតាមគោលនយោបាយអភិវឌ្ឍ ជាតិ និង ខេត្ត ក្រុង។

**ជំហានទី៤ : ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និង ថវិកា រៀបចំតារាងថវិកា វិនិយោគតាមប្រភព តារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និង តារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ ព្រមទាំងជ្រើសរើសគម្រោងដែលមិនទាន់មានការសន្យាគាំទ្រ សម្រាប់ប្រើប្រាស់មូលនិធិឃុំ សង្កាត់។ លើសពីនេះទៅទៀតគណៈកម្មាធិការកសាងផែនការ និង ថវិកា រៀបចំការប្រជុំ ផ្សព្វផ្សាយនៅតាមភូមិ ដើម្បីឲ្យប្រជាពលរដ្ឋផ្តល់យោបល់លើគម្រោងវិនិយោគប្រចាំឆ្នាំ ជាពិសេសគម្រោងប្រើប្រាស់មូលនិធិឃុំ សង្កាត់។ ហើយគណៈកម្មាធិការកសាងផែនការ និង ថវិកា ត្រូវធ្វើការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគ ឃុំ សង្កាត់ និងដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និង អនុម័ត។ ហើយឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ និង បង្កភាពងាយស្រួល ដល់អ្នកពាក់ព័ន្ធធ្វើការសិក្សាស្វែងយល់អំពីវា។

**ជំហានទី៥ : ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ សង្កាត់**

ការតាមដានត្រួតពិនិត្យការរីកចម្រើន និង ប្រសិទ្ធភាពនៃការអនុវត្ត គម្រោង ឬ សកម្មភាពនានា ដែលមាននៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីធានាការអនុវត្តគម្រោង ឬ សកម្មភាពទាំង

នោះឲ្យ បានត្រឹមត្រូវ និង ទាន់ពេលវេលា។ ជាពិសេសថែមទាំងមានការពិនិត្យ និង វាយតម្លៃលើប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីវិនិយោគឃុំ សង្កាត់ និង ដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និង ការរៀបចំកម្មវិធីវិនិយោគឆ្នាំ ក្រោយបន្តទៀត។

## ២.៧ ការអនុវត្ត និង តាមដាន ផែនការឃុំ សង្កាត់

នៅពេលអនុវត្តគម្រោងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ពិសេសអ្នកទទួលផលគម្រោង បានចូលរួមយ៉ាងពេញលេញ នៅក្នុងការរៀបចំគម្រោង និង ការត្រួតពិនិត្យការអនុវត្តគម្រោងដែលមាននៅក្នុងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់។ ហើយមេឃុំ ចៅសង្កាត់ ត្រូវធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈឬ ទំនិញនិងសេវាកម្ម ដើម្បីអនុវត្ត គម្រោងទាំងអស់ និង សកម្មភាពនានាឲ្យស្របទៅតាមនីតិវិធីដែលបានកំណត់។ ហើយមុនធ្វើលទ្ធកម្មការងារសាងសង់សម្ភារៈឬទំនិញ និង សេវាកម្ម សម្រាប់អនុវត្តគម្រោងណាមួយ មេឃុំ ចៅសង្កាត់ ត្រូវស្វែងរកការបញ្ជាក់ផ្នែកបច្ចេកទេសពីមន្ទីរជំនាញ ឬ អង្គភាពពាក់ព័ន្ធជុំវិញ ខេត្ត ក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដើម្បីចៀសវាងនូវភាពមិនប្រក្រតី។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតាមដានការរីកចម្រើន នៃការតាមដានការអនុវត្តផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគឃុំ សង្កាត់ និង បណ្ដាសកម្មភាព ដែនបានអនុវត្តនៅក្នុងដែនដីឃុំ សង្កាត់របស់ខ្លួន ដោយអង្គភាព រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និង ផ្នែកឯកជន។ ហើយការតាមដានការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មិនត្រូវបង្កឲ្យរាំងស្ទះដល់អង្គភាពពាក់ព័ន្ធ ដែលត្រូវធ្វើការតាមដានវាយតម្លៃសកម្មភាពនានា ទាក់ទងនិងគម្រោងដែលគេកំពុងគាំទ្រនៅឃុំ សង្កាត់នោះឡើយ។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឲ្យមានការអន្តរាគមន៍រហ័សក្នុងការដោះស្រាយបញ្ហា និង ការលំបាកនានា ដែលកើតឡើងជាយថាហេតុក្នុងអំឡុងពេល ការអនុវត្តផែនការ អភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ សង្កាត់។ ហើយក្រសួងមហាផ្ទៃត្រូវចេញសម្រេចស្ដីណែនាំស្ដីពីបែបបទការវាយតម្លៃ ដោយពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ។ការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល និង ផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍ ឃុំ សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេល ៦ ខែចុងក្រោយ នៃអាណត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ហើយក្រសួងមហាផ្ទៃត្រូវចេញសម្រេចស្ដីណែនាំស្ដីពីបែបបទការវាយតម្លៃ ដោយពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ។

ដូចនេះគេនិយាយថាផែនការអភិវឌ្ឍនៅមូលដ្ឋានអាចជួបប្រទះបញ្ហាជាច្រើន ហើយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតែមានដដែល ដោយសារមានភាពខុសគ្នារវាងឃុំ ដែលមានធនធាន និង ឃុំដែលគ្មានធនធាន។ ការធ្វើសន្និដ្ឋានបែបនេះមិនមែនមានន័យថា បញ្ហាអភិវឌ្ឍនៅមូលដ្ឋានដែលត្រូវអនុវត្តតាមគោលនយោបាយវិមជ្ឈការ មានភាពល្អឥតខ្ចោះនោះទេ។ មានបញ្ហាជាច្រើនដូចជាអភិបាលកិច្ចមូលដ្ឋាននៅមានកម្រិត និង គ្មានការទទួលខុសត្រូវចំពោះមុខច្បាប់របស់មេឃុំ ចៅសង្កាត់ដែលបំពេញការងារមិនបានត្រឹមត្រូវច្រើនពេក។ ជាមួយនេះមានបញ្ហាមួយចំនួនទៀត ក៏អាចនិងត្រូវលើកឡើងផងដែរ នៅក្នុងបញ្ហានៃការកសាងផែនការអភិវឌ្ឍនោះ គឺ បញ្ហាការចូលរួមរបស់ប្រជាពលរដ្ឋ ទៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍនោះ នៅមានកម្រិតទាបនៅឡើយ ហើយភាគច្រើនណាស់ដែលប្រជាពលរដ្ឋយើងមិនអាច និង ទទួលបាននូវព័ត៌មានឲ្យបានពេញលេញ ស្តីពីការងារ គ្រប់គ្រងរបស់រាជការយើងទេ។

# ជំពូកទី ៣

# របកគំហើញនៃការស្រាវជ្រាវ

## ៣.១ សមិទ្ធផល គិតត្រឹមឆ្នាំ ២០១១

ការអនុវត្តនយោបាយវិមជ្ឈការ នៅថ្នាក់ ឃុំ សង្កាត់ គឺ មានសារៈសំខាន់ខ្លាំងណាស់ ដូចនេះ អាជ្ញាធរមូលដ្ឋាន ត្រូវតែខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាព។ ដើម្បីធានាឲ្យមានការចាប់ផ្ដើមអនុវត្ត ប្រកបដោយតម្លាភាព និង មានប្រសិទ្ធភាពនូវសកម្មភាពជាច្រើនរបស់ខ្លួន ដែលចាប់ផ្ដើមពីការបោះឆ្នោតតាំងពីឆ្នាំ ២០០២ មក ។ ក្រោយពីការបោះឆ្នោតនៅឃុំ សង្កាត់ អាស្រ័យដោយមានការត្រៀមរៀបចំយ៉ាងម៉ត់ចត់ អាជ្ញាធរមូលដ្ឋាននេះ បានចាប់ផ្ដើមដំណើរការ ដែលក្នុងរយៈពេលស្ថិតនៅក្នុងការគ្រប់គ្រងតាមបែបវិមជ្ឈការរបស់ខ្លួន និង សម្រេចបានសមិទ្ធផលដូចខាងក្រោមៈ

### ៣.១.១ ការធ្វើប្រតិភូកម្មមុខងារជាក្លាក់ងារនៅឲ្យ ឃុំ សង្កាត់

នៅក្នុងការអនុវត្តវិមជ្ឈការ ឃុំ សង្កាត់នេះមាន មុខងារជាក់លាក់ចំនួនពីរ ដែលត្រូវបានធ្វើប្រតិភូកម្មអំណាចដោយច្បាប់ និង លិខិតបទដ្ឋានទៅឲ្យឃុំ សង្កាត់គឺៈ

ការចុះបញ្ជីអត្រានុកូលដ្ឋាន កំណើត អាពាហ៍ពិពាហ៍ និង មរណៈដែល មុខងារទាំងនេះបានផ្ដល់ ទៅឲ្យឃុំ សង្កាត់ អនុវត្តចាប់ពីការបោះឆ្នោតនៅឆ្នាំ ២០០២ មកម្លេះ។ ក្នុងការគ្រប់គ្រងមុខងារនេះថ្នាក់ជាតិបានធ្វើការគាំទ្រសមត្ថភាព ដល់ឃុំ សង្កាត់ បានមួយកំរិត តាមរយៈការបណ្ដុះបណ្ដាលដល់ស្មៀនឃុំ សង្កាត់ ការផ្ដល់ការណែនាំ និង ការគាំទ្រ ជាប្រចាំដោយថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ទន្ទឹមនិងនេះចំណូល ដែលទទួលបាន ពីអត្រានុកូលដ្ឋាន នៅឃុំ សង្កាត់ ត្រូវបានផ្ទេរជាចំណូលប្រចាំរបស់ឃុំ សង្កាត់ ដើម្បី ឲ្យឃុំ សង្កាត់ ចំណាយសម្រាប់អនុវត្តមុខងារនេះ។ ប៉ុន្តែទោះជាយ៉ាងណាក្តី មុខងារទាមទារឲ្យមានការ ពង្រឹង និង កែលម្អជាបន្ថែមទៀត សំដៅលើកំពស់ការទទួលខុសត្រូវការអនុវត្ត ។

ការរៀបចំបញ្ជីឈ្មោះ និង ចុះឈ្មោះអ្នកបោះឆ្នោត ដែលការងារនេះត្រូវបានផ្ដល់ទៅឲ្យឃុំ សង្កាត់ អនុវត្តចាប់ពីការបោះឆ្នោតជាតិលើកទី៣ ហើយមុខងារនេះ និង ត្រូវអនុវត្តជារៀងរាល់ឆ្នាំ ដោយឃុំ សង្កាត់ ។ លើសពីនេះទៅទៀតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) ដែលជាស្ថាប័នធ្វើប្រតិភូកម្ម អំណាច បានផ្ដល់ការបណ្ដុះបណ្ដាលជូនក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្មៀន ឃុំ សង្កាត់ សម្រាប់ជំហាន ចាប់ផ្ដើម ការអនុវត្តតែប៉ុណ្ណោះ។ រីឯធនធានសម្រាប់ចំណាយមួយផ្នែកធំ ស្ថិត

ក្នុងបន្ទុករបស់ (គ.ជ.ប) ជាអ្នកចំណាយផ្ទាល់។ ឃុំ សង្កាត់ គ្រាន់តែបានទទួលសារហ៊ុយសម្រាប់ឧបត្ថម្ភស្បៀនតែប៉ុណ្ណោះ។

សរុបមកមុខងារដែលបានផ្តល់ឲ្យឃុំ សង្កាត់ គឺ ជាដំណើរការចាប់ផ្តើមប៉ុណ្ណោះ ហើយដំណើរការចាំបាច់ធ្វើការពិនិត្យ មើលឲ្យបានល្អិតល្អន់ ទាំងសមត្ថភាព ការទទួលខុសត្រូវ ធនធាន និង ប្រសិទ្ធភាពដែលទទួលបាន ដើម្បីឲ្យថ្នាក់ជាតិអាចពិចារណា និង ផ្ទេរការងារផ្សេងទៀតទៅឲ្យ ឃុំ សង្កាត់ ធ្វើការងារជាភ្នាក់ងារ ក្នុងការឆ្លើយតបទៅនិងភាពជាក់ស្តែងនៅក្នុងសង្គម។

### ៣.១.២ ការរៀបចំតាក់តែងលិខិតបទដ្ឋាន

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានបែងចែកអ្វីដែលជាគោលការណ៍និងជាលក្ខណៈតម្រង់ទិសដើម្បីអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការឲ្យមានប្រសិទ្ធភាព។ ដើម្បី បម្រើឲ្យមានការអនុវត្តច្បាប់នេះ ប្រកបដោយតម្លាភាព ចាំបាច់ គឺ ត្រូវឲ្យមានការរៀបចំលិខិតបទដ្ឋានជាច្រើនទៀត ឲ្យបានទាន់ពេលវេលា សម្រាប់ជាមូលដ្ឋាន ឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ អនុវត្តភារកិច្ចរបស់ខ្លួន ពីដំណាក់កាលមួយទៅដំណាក់កាលមួយស្របតាមសមត្ថភាព និង ធនធានដែលមានដើម្បីធ្វើការ ដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួនឲ្យបានទាន់ពេលវេលា និង ចំគោលដៅ ព្រោះពួកគាត់ដឹងយ៉ាងច្បាប់អំពីការធ្វើលិខិតទាំងនោះនៅមូលដ្ឋាន។

### ៣.១.៣ ហិរញ្ញវត្ថុឃុំ សង្កាត់

វិមជ្ឈការហិរញ្ញវត្ថុ គឺ ជាបញ្ហាដ៏ស្មុកស្មាញបំផុត នៅប្រទេសកម្ពុជា ទោះបីជាកំណែទម្រង់មានសភាពពិបាកបន្តិចបន្តួច ក៏ដោយ យើងសង្កេតឃើញមានលក្ខណៈពិសេសមួយចំនួនសម្រាប់រដ្ឋបាលឃុំ សង្កាត់ដូចជាៈ

- មានថវិកាដោយឡែកសម្រាប់ក្រុមប្រឹក្សា
- ការកំណត់ភាគរយនៃប្រាក់ចំណូលជាតិ សម្រាប់ផ្តល់ទៅឲ្យថវិកាឃុំ សង្កាត់ នៅក្នុងរយៈពេលដែលបានកំណត់ជារៀងរាល់ឆ្នាំ។
- តំណាងរបស់ឃុំ សង្កាត់នៅក្នុងក្រុមប្រឹក្សាភិបាលបែងចែកថវិកា
- ការផ្តល់ទុនបដិភាគពីប្រភពខាងក្រុមដល់មូលនិធិឃុំ សង្កាត់
- ការផ្តល់ថវិកាទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និង ការអនុវត្តការងារ

- ការកំណត់ឲ្យមានការត្រួតពិនិត្យ ដោយអាជ្ញាធរនៅថ្នាក់លើ ទាក់ទងទៅនិង ជំនួយវិភាគន៍ និង ការគ្រប់គ្រងហិរញ្ញវត្ថុ
- ការសម្របសម្រួលអន្តរក្រសួង នៅក្នុងចំណោមក្រសួងសំខាន់ៗ ដូចជាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ
- ការកំណត់ឲ្យមានប្រភពចំណូលផ្ទាល់របស់ក្រុមប្រឹក្សា ដោយស្ថិតនៅក្រោមច្បាប់។
- ការធ្វើប្រតិភូកម្មមុខងារជាភ្នាក់ងារទៅឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់ អមទៅដោយធនធានហិរញ្ញវត្ថុ ចាំបាច់ និង ប្រព័ន្ធធ្វើសវនកម្ម។

ក្រុមប្រឹក្សា ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុពីរយ៉ាង គឺ ជំនួយវិភាគរបស់រាជរដ្ឋាភិបាល និង ប្រភពចំណូលផ្ទាល់ខ្លួន។ ជំនួយវិភាគន៍ត្រូវគ្រប់គ្រងតាមរយៈមូលនិធិឃុំ សង្កាត់ ដែលមានភាគរយនៃប្រាក់ចំណូល របស់ជាតិ ទុនបដិភាគរបស់អ្នកផ្តល់ជំនួយ និង ប្រាក់កំចីពីទីភ្នាក់ងារ អន្តរជាតិ។ ចំពោះ ចំណូលផ្ទាល់ខ្លួនក្រុមប្រឹក្សាឃុំ សង្កាត់ មានអំណាចយកពន្ធ និង កំរៃសេវា( មាត្រា ៧៤ នៃ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) ប៉ុន្តែច្បាប់ស្តីពីចំណូលផ្ទាល់ខ្លួនរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ នៅមិន ទាន់បានរៀបចំនៅឡើយ ហើយក្រុមប្រឹក្សា ឃុំ សង្កាត់ ក៏មិនអាចខ្ចីប្រាក់បានដែរ។

### ៣.១.៤ ជំនួយវិភាគន៍ផ្តល់ឲ្យក្រុមប្រឹក្សា ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិទទួលជំនួយវិភាគន៍ផ្នែករដ្ឋបាល និង ផ្នែកអភិវឌ្ឍឃុំ សង្កាត់។ ប្រាក់ផ្ទេរពីហិរញ្ញវត្ថុឃុំ សង្កាត់ ត្រូវបានបែងចែកជាផ្នែករដ្ឋបាល (១/៣ នៃធនធាន) និង ផ្នែកអភិវឌ្ឍ (២/៣ នៃធនធាន)។ ផ្នែករដ្ឋបាលរួមមានចំណាយលើបៀវត្ស និង ការចំណាយជាមូលដ្ឋាន នៅក្នុងផ្នែករដ្ឋបាល ត្រូវបានគណនាដោយផ្អែកលើ ចំនួនក្រុមប្រឹក្សា។ ផ្នែកអភិវឌ្ឍត្រូវបានគណនេយ្យដោយផ្អែកលើ មូលដ្ឋាននៃការបែងចែកស្មើគ្នាសម្រាប់ក្រុមប្រឹក្សាទាំងអស់ សមាមាត្រប្រជាជន និង សន្ទស្សន៍នៃភាពក្រីក្រ តំណាងឲ្យទឹកប្រាក់យ៉ាងហោចណាស់ ៥០% នៃទឹកប្រាក់ទាំងអស់នៅក្នុងការអភិវឌ្ឍ។

ក្នុងការទទួលប្រាក់ពីហិរញ្ញវត្ថុ ឃុំ សង្កាត់ ក្រុមប្រឹក្សាត្រូវបានបែងចែកជាប្រភេទទី១ (ជាក្រុមប្រឹក្សា ដែលមានសមត្ថភាពខ្ពស់) និង ប្រភេទទី២ ( ជាក្រុមប្រឹក្សាដែលពុំសូវមានសមត្ថភាព)។ ក្រុមប្រឹក្សា នៅក្នុងប្រភេទទី១ ទទួលថវិកា ក្រោមជំនួយវិភាគន៍អភិវឌ្ឍច្រើនជាងប្រភេទទី២ ក្រុមប្រឹក្សានៅក្នុងប្រភេទទី២ ទទួលបានជំនួយតែក្នុងផ្នែករដ្ឋបាលតែប៉ុណ្ណោះ។ នៅឆ្នាំ ២០០៣ ក្រុមប្រឹក្សាទាំងអស់ ទទួលបានជំនួយវិភាគន៍ ទាំងផ្នែករដ្ឋបាលនិងផ្នែកអភិវឌ្ឍ ប៉ុន្តែក្រុមប្រឹក្សានៅក្នុងប្រភេទទី២

ទទួល បានជំនួយតិចជាង ប្រភេទទី១។ ប៉ុន្តែចាប់ពីឆ្នាំ២០០៤ ឡើងទៅ លេងមានភាពខុសគ្នាបែបនេះទៀតហើយ។

### ៣.១.៥ កត្តាគោលនយោបាយ

រាជរដ្ឋាភិបាលបានកំណត់គោលដៅជាចម្បងនៃ ការកំណែទម្រង់វិមជ្ឈការ ចំនួនបីគឺការពង្រឹង និង ពង្រីកប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន ការលើកកម្ពស់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ច និង ការកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋានឃុំ សង្កាត់ នីមួយៗ។ រហូតមកដល់ពេលនេះការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ បានប្រព្រឹត្តទៅយ៉ាងរលូនទៅតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ។ ជាក់ស្តែងនៅក្នុងរយៈពេលជាង ៣ ឆ្នាំកន្លងមកនេះមិនមានក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ នៅក្នុងអាណត្តិទី២ ត្រូវបានអន្តរាគមន៍ថ្នាក់ជាតិ ឬ ត្រូវបានរំសាយឡើយ។ការបង្កើតនៃក្រុមប្រឹក្សានៃរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ បាននាំឲ្យមានការចូលរួមពីក្រុមដែលមាននិន្នាការនយោបាយខុសៗគ្នានៅមូលដ្ឋាន រួបរួមគ្នាអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈដំណើរការកសាងផែនការអភិវឌ្ឍ ការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការដោះស្រាយបញ្ហានានានៅមូលដ្ឋាន ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងអនុវត្តគម្រោងអភិវឌ្ឍរបស់រដ្ឋបាលឃុំ សង្កាត់ និង គម្រោងសហប្រតិបត្តិការ នានាជាច្រើនទៀត។

### ៣.១.៦ គណនេយ្យភាព និង តម្លាភាព

នៅក្នុងគោលដៅការអនុវត្តនៅថ្នាក់ឃុំ សង្កាត់ តាមបែបវិមជ្ឈការបានផ្តោតទៅលើការពង្រឹងអភិបាលកិច្ចដែលមានគណនេយ្យភាព និង តម្លាភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ការរៀបចំនិងអនុវត្តថវិកា កិច្ចលទ្ធកម្មគម្រោង និង ការរៀបចំគម្រោង សុទ្ធតែបានអនុវត្តតាមនីតិវិធីដែលបានធានាការចូលរួមតម្លាភាព គណនេយ្យភាព ការឆ្លើយតប សុវត្ថិភាពបរិស្ថាន ប្រសិទ្ធភាព និង ប្រសិទ្ធផល។

នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់ខ្លួន ក្រុមប្រឹក្សានៃរដ្ឋបាលឃុំ សង្កាត់បានរៀបចំរបាយការរីកចម្រើន និង របាយការណ៍អនុវត្តថវិកាប្រកបដោយតម្លាភាព ដោយបានផ្សព្វផ្សាយរបាយការណ៍ទាំងនោះជាសាធារណៈតាមរយៈក្តារព័ត៌មានសាធារណៈរបស់ឃុំ សង្កាត់ និង បានផ្តល់លទ្ធភាពដល់សាធារណៈជនក្នុងការទទួលបានរបាយការណ៍ទាំងនេះ។ ការប្រើប្រាស់ក្តារព័ត៌មានសាធារណៈ ការផ្សព្វផ្សាយអំពីរបាយការណ៍នានា ដែលប្រជាពលរដ្ឋអាចទទួលបានព័ត៌មាននានាជុំវិញការអនុវត្តភារកិច្ច និង ការផ្តល់សេវាសាធារណៈនានា ត្រូវបានយកចិត្តទុកដាក់ជាខ្លាំងពី

ក្រុមប្រឹក្សាឃុំ សង្កាត់

### ៣.១.៧ ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន

ការកាត់បន្ថយភាពក្រីក្រគឺ ជាទិសដៅមួយនៃគោលនយោបាយវិមជ្ឈការនៅឃុំ សង្កាត់ ហើយរាជរដ្ឋាបាលភិបាលបានកំណត់ចំនួនទឹកប្រាក់សម្រាប់ជំនួយវិភាជន៍អភិវឌ្ឍឃុំ សង្កាត់ ដោយផ្អែកទៅលើសន្ទស្សន៍នៃភាពក្រីក្រ ដែលនាំឲ្យការអនុវត្តប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាបាលភិបាលបានចាប់ផ្តើមអនុវត្តគោលនយោបាយនេះ ដោយមានកត្តាជាច្រើនចូលរួមកាត់បន្ថយភាពក្រីក្រ ដូចជា ការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងដំណើរការកសាងផែនការដែលមានការចូលរួមក្នុងការការកំណត់តម្រូវការអភិវឌ្ឍនៅមូលដ្ឋានការចូលរួមគាំទ្រគម្រោងអភិវឌ្ឍរបស់ឃុំ សង្កាត់ ដោយសប្បុរសជន និង អង្គការមិនមែនរាជរដ្ឋាភិបាលនានាជាច្រើន។

ដូចនេះការកាត់បន្ថយភាពក្រីក្រស្តែងឡើងនៅក្នុងការអនុវត្តគម្រោងអភិវឌ្ឍឃុំ សង្កាត់នានាដែលជាទូទៅគម្រោងទាំងនោះមានចរឹតជាគម្រោងវិនិយោគខ្នាតតូចៗ ដែលជាគម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងលើកកម្ពស់ជីវភាពរស់នៅ ឬ គម្រោងបង្កើនប្រាក់ចំណូល និងគម្រោងសេវានានាក្នុងគោលដៅដោះស្រាយតម្រូវការជាបន្ទាន់នៅមូលដ្ឋាន និង លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឲ្យកាន់តែប្រសើរឡើងៗ។

## ៣.២ បញ្ហាប្រឈម

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះ រដ្ឋបាលឃុំ សង្កាត់បានដំណើរការតាមបែបប្រព័ន្ធ វិមជ្ឈការ។ ហើយវិមជ្ឈការ នៅថ្នាក់ ឃុំ សង្កាត់នេះនិងនាំមកនូវវិបត្តិមួយចំនួនដូចជាៈ

### ៣.២.១ ការចូលរួម និង ភាពជាម្ចាស់

ការពិគ្រោះយោបល់និងការចូលរួម គឺជាគោលការណ៍មួយក្នុងចំណោម គោលការណ៍ទាំង៩ក្នុងការអនុវត្តតាមបែបប្រជាធិបតេយ្យ។ កន្លងមកទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីគ្រប់អ្នកពាក់ព័ន្ធ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការផ្សព្វផ្សាយតាមរូបភាពណាក៏ដោយ ក៏ការចូលរួមនៅកិច្ចការក្នុងមូលដ្ឋាននៅមានកម្រិតនៅឡើយ ពិសេស ជនក្រីក្រ ស្ត្រី យុវជន និង ជនងាយរងគ្រោះ ជនជាតិដើមភាគតិចក្នុងការចូលរួមក្នុងការលើកឡើងនូវបញ្ហានិង តម្រូវការជាអាទិភាពរបស់ខ្លួនសម្រាប់ដាក់ចូលក្នុងផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់ ដើម្បីជានានូវការដោះ

ស្រាយបញ្ហា និង តម្រូវការទាំងនោះ។

### ៣.២.២ ធនធានហិរញ្ញវត្ថុ

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានចំណូល តែពីប្រភពមូលនិធិឃុំ សង្កាត់ ពីប្រភពទុនចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និង ប្រភពដៃគូរអភិវឌ្ឍតាមរយៈគម្រោង កម្មវិធីនានាប៉ុណ្ណោះ។ ចំណូលផ្ទាល់ដែលរួមមាន ប្រភពចំណូលសារពើពន្ធ ប្រភពចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗនៅមិនទាន់មានការសិក្សា និង ពិចារណានៅឡើយ។ ទន្ទឹមនេះក្រុមប្រឹក្សាឃុំ សង្កាត់ មិនទាន់ទទួលបានចំណូលណាមួយសម្រាប់ការអនុវត្តមុខងារជាជម្រើសនានានៅឡើយ ក្រៅថវិកាប្រតិបត្តិការដែលស្ថិតក្រោមថវិកាឃុំ សង្កាត់។ បញ្ហាទាំងនេះមានការស្មុកស្មាញដែលទាមទារឲ្យមានការសិក្សាស៊ីជម្រៅ និងមានការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងរាជរដ្ឋាភិបាល។ អវត្តមាននៃប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់ វានិងធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ដែលជាគ្រឹះនៃប្រធិបតេយ្យ។

### ៣.២.៣ ធនធានមនុស្ស និង ការអភិវឌ្ឍសមត្ថភាព

បន្ទាប់ពីរៀបចំរចនាសម្ព័ន្ធថ្មីស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់មន្ត្រីទាំងអស់ទាមទារឲ្យមានវិជ្ជាជីវៈច្បាស់លាស់ ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារស្របទៅតាមអាណត្តិរបស់ខ្លួន។ ដោយសារនៅថ្នាក់ឃុំ សង្កាត់ មានតែបុគ្គលិកម្នាក់គត់គឺ ស្មៀនឃុំ សង្កាត់ ហេតុការបណ្តុះបណ្តាល់អភិវឌ្ឍសមត្ថភាពកន្លងមក ត្រូវបានធ្វើឡើងសម្រាប់ទាំងក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្មៀនឃុំ សង្កាត់។ ដូចនេះនៅរាល់អាណត្តិថ្មីនៃក្រុមប្រឹក្សាឃុំ សង្កាត់ ការបណ្តុះបណ្តាលឡើងវិញគឺប្រការចៀសមិនផុត ដែលធ្វើឲ្យរាជរដ្ឋាភិបាលត្រូវប្រើប្រាស់ធនធានជាច្រើន ទៅលើការអភិវឌ្ឍសមត្ថភាព។

### ៣.២.៤ ប្រព័ន្ធ និងរចនាសម្ព័ន្ធ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឲ្យមានការរៀបចំរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ដែលមានសិទ្ធអំណាច ស្វ័យភាពការទទួលខុសត្រូវ មុខងារ ធនធាន និង សមត្ថភាពសមស្របដើម្បីដោះស្រាយសេចក្តីត្រូវការ និងការអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប៉ុន្តែការអនុវត្តតាមបែបវិមជ្ឈការនេះ រាជរដ្ឋាភិបាល បានរៀបចំប្រព័ន្ធ និង រចនាសម្ព័ន្ធសម្រាប់រដ្ឋបាលឃុំ សង្កាត់ក៏ពិតមែន ក៏ប្រព័ន្ធ និង រចនាសម្ព័ន្ធនេះមិនទាន់ដំណើរការដោយរលូន និង ប្រកបដោយប្រសិទ្ធភាព

នៅឡើយទេ។ លើសពីនេះទៅទៀតប្រព័ន្ធកសាងផែនការ និង ប្រព័ន្ធរៀបចំផែនការនៅមិនទាន់ស៊ីសង្វាក់គ្នា ដែលទាមទារឲ្យមានការពិនិត្យនិងកែសម្រួលឲ្យបានសមស្រប។ ហើយប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធតាមដាននិងវាយតម្លៃរួមទាំងប្រព័ន្ធរបាយការណ៍នៅមិនទាន់បានរៀបចំនៅឡើយ។

## ៣.៣ ដំណោះស្រាយ

### ៣.៣.១ ការចូលរួម និង ភាពជាម្ចាស់

យើងត្រូវតែយកចិត្តទុកដាក់បន្ថែមទៀតដល់ការជំរុញលើកចិត្តឲ្យស្ត្រី និង ជនងាយរងគ្រោះបានលើកបញ្ហាតម្រូវការចាំបាច់ជាក់ស្តែង របស់ពួកគាត់ នៅពេលដែលចូលរួមលើកមតិយោបល់នៅក្នុងអង្គប្រជុំ។ ជាពិសេសកិច្ចប្រជុំប្រចាំខែ របស់ក្រុមប្រឹក្សាគួរចល័ត ការប្រជុំតាមភូមិ ( ឧទាហរណ៍: ខែមករា នៅភូមិ"ក" និង ខែកុម្ភៈ នៅភូមិ "ខ" ដើម្បីងាយស្រួលដល់ប្រជាពលរដ្ឋចូលរួម ហើយត្រូវអញ្ជើញជនបង្គោល អ្នកពាក់ព័ន្ធផ្សេង និង ប្រជាពលរដ្ឋ ចាស់ព្រឹទ្ធាចារ្យបានចូលរួមស្តាប់ និង ផ្តល់យោបល់ដល់អង្គប្រជុំ ដើម្បីដឹងច្បាស់ និង ទទួលយកអនុសាសន៍ ពីបញ្ហាប្រឈមនានាដែលបានកើតឡើងនៅក្នុងមូលដ្ឋាន ដើម្បីងាយស្រួលក្នុងការ ដោះស្រាយ ចាត់វិធានការទាន់ពេលវេលានិង ចំគោលដៅច្បាស់លាស់។

### ៣.៣.២ ធនធានហិរញ្ញវត្ថុ

- ត្រូវរៀបចំឲ្យមានប្រភពចំណូលផ្ទាល់នៃថវិកា ឃុំ សង្កាត់ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តិ ចាំបាច់នានាសម្រាប់ឃុំ សង្កាត់ ដើម្បីឲ្យមានភាពសមាមាត្រគ្នា។
- ពង្រឹងការប្រមូល ការគ្រប់គ្រង និង ការចាត់ចែង ប្រភពចំណូលពីសោហ៊ុយ និង ការអនុវត្ត
- ការងារ ជាភ្នាក់ងារ របស់ឃុំ សង្កាត់ លើមូលដ្ឋាននៃការសិក្សាពិចារណា មុខងារភ្នាក់ងារដែលបានធ្វើប្រតិភូកម្មកន្លងមក និង ការធ្វើប្រតិភូកម្មមួយចំនួនទៀតបន្ថែម។
- ពង្រឹងសមត្ថភាពរបស់ឃុំ សង្កាត់ ក្នុងការរៀបចំ ការអនុម័ត និង ការអនុវត្តថវិកា របស់ខ្លួនឲ្យមាន តម្លាភាព គណនេយ្យភាព នៅក្នុងភារកិច្ចការងាររបស់ខ្លួន។
- ដំណើរកសាងសាលាឃុំ សង្កាត់ និង ការបំពាក់មធ្យោបាយសម្ភារៈ ធ្វើការរបស់ឃុំ សង្កាត់តាមជំហានៗដែលបានកំណត់ ដើម្បីធានានូវប្រសិទ្ធភាពការងារ។

### ៣.៣.៣ ធនធានមនុស្សនិងការអភិវឌ្ឍសមត្ថភាព

បង្កើនមានការរៀបចំឲ្យមានយុត្តិសាស្ត្រសម្រាប់ការបណ្តុះបណ្តាល ដោយឈរលើមូលដ្ឋាននៃការត្រួតពិនិត្យ និង វាយតម្លៃ យ៉ាងច្បាស់លាស់អំពីការ វិវត្តន៍ រីកចម្រើននៃសមត្ថភាពរបស់ឃុំ សង្កាត់

- រៀបចំបណ្តុះបណ្តាលមន្ត្រីសំខាន់ៗនៅថ្នាក់ឃុំ សង្កាត់។
- រៀបចំយន្តការសមស្របសម្រាប់ការបង្កើនសមត្ថភាពគ្រប់ថ្នាក់អំពីវិមជ្ឈការ។
- បង្កើនការអប់រំសាធារណៈជនឲ្យបានកាន់តែទំលំទូលាយថែមទៀត។
- រៀបចំធ្វើអត្ថបណែនាំ សៀវភៅកាន់ដៃអំពីរដ្ឋបាលមូលដ្ឋាន និង សន្ទនានុក្រម ដែលលើកឡើង អំពីគោលការណ៍សំខាន់ៗ នៃអភិបាលកិច្ចឃុំ សង្កាត់ដោយភាសាសាមញ្ញ ខ្លី ងាយយល់ ដោយ ឈរលើមូលដ្ឋានច្បាប់ ដើម្បីងាយស្រួលឲ្យថ្នាក់មូលដ្ឋានធ្វើស្វ័យសិក្សា ស្វែងយល់ និង អនុវត្ត គោលនយោបាយឲ្យមានប្រសិទ្ធភាព។

### ៣.៣.៤ ប្រព័ន្ធ និង រចនាសម្ព័ន្ធ

ជំរុញឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀតដល់ការពង្រឹងការគ្រប់គ្រងរដ្ឋបាលនៅឃុំ សង្កាត់ឲ្យក្លាយជារដ្ឋបាលមូលដ្ឋានថ្មីមួយទៀត សំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិការ របស់ឃុំ សង្កាត់ក្នុងការផ្តល់សេវា និង ការអភិវឌ្ឍមូលដ្ឋានឲ្យបានកាន់តែទូលំទូលាយ និង ប្រកប ដោយប្រសិទ្ធភាព ព្រោះ ព្រោះរដ្ឋបាលទាំងនោះអាចមានលទ្ធភាពម្ចាស់ការ បំពេញការងាររបស់ខ្លួនដោយ ខ្លួនឯងបានជាជំហានៗ។

# សេចក្ដីសន្និដ្ឋាន

ការអនុវត្តតាមបែបវិមជ្ឈការនៅថ្នាក់ ឃុំ សង្កាត់ គឺ ជាកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ហើយវាមានគោលបំណងផ្ដល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋានជាពិសេស ក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋ និង ក្រុមជនងាយរងគ្រោះនានាអាចមានសិទ្ធិចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និង ការផ្ដល់សេវាសាធារណៈនៅមូលដ្ឋានឲ្យមានប្រសិទ្ធភាព តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និង ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការពិនិត្យតាមដានលើការងារ ថវិកា និង ការបំពេញការងាររបស់រដ្ឋបាលនៅ មូលដ្ឋាន ហើយវាក៏ជាដំណើរការ នៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និង រដ្ឋបាលថ្នាក់មូលដ្ឋានផងដែរ។ លើសពីនេះទៅទៀតវាក៏ជាមធ្យោបាយមួយដែលបន្សុីគ្នារវាង គោលការណ៍ ទាំងឡាយ នៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើ សេចក្ដីសម្រេចចិត្ត និង ការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានប្រកាន់យកតាមកិច្ចដំណើរតាមបែបប្រជាធិបតេយ្យ ហើយជាទូទៅ កិច្ចដំណើរការនេះ រួមមានរាល់សកម្មភាពទាំងឡាយណាដែលផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋ និង តំណាងរបស់ខ្លួនអាចការពារនូវផលប្រយោជន៍របស់ខ្លួន និង ពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និង អ្នកផ្ដល់សេវាកម្មនានាដែលជាអ្នកអនុវត្តសេចក្ដីសម្រេចចិត្តទាំងឡាយពាក់ព័ន្ធ សិទ្ធិ និង ធនធាន ហើយការផ្ដល់សេវាកម្មនៅមូលដ្ឋានគឺត្រូវតែសមស្របទៅតាមតម្រូវការចាំចាច់របស់ ប្រជាពលេរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជាពិសេសការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ តាមបែបវិមជ្ឈការ គឺ ជាការរៀបចំនូវយន្តការនានានៃការប្រាស្រ័យទាក់ទងគ្នាដ៏ច្បាស់លាស់ និង មានប្រសិទ្ធភាពរវាងតួអង្គចំនួនពីរក្រុម ពោល គឺ ក្រុមប្រជាពលរដ្ឋ និង រដ្ឋបាលឃុំ សង្កាត់ ដែលត្រូវមានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។

ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ គឺ ជាចលនាមួយយ៉ាងសំខាន់ក្នុងការចូលរួមផ្ដល់មតិយោបល់រៀបចំផែនការ ផ្សព្វផ្សាយនូវគោលការណ៍ និង អនុវត្តផែនការ យ៉ាងមានប្រសិទ្ធភាព និង តម្លាភាព ពីព្រោះពួកគាត់នៅជាប់ជាមួយប្រជាពលរដ្ឋ គាត់ដឹងនូវរាល់បញ្ហាដែលកើតមានឡើងក្នុង ឃុំ សង្កាត់ របស់គាត់។ ដូចនេះ បើមូលដ្ឋានគ្រឹះរឹងមាំ វានិងនាំជាតិរឹងមាំ គឺ ដោយសារប្រជាជនគ្រប់រូប មាន គុណធម៌ សីលធម៌ សេចក្ដីថ្លៃថ្នូរ ចូលរួមបំពេញភារកិច្ច កាតព្វកិច្ច ឲ្យបានពេញលេញនៅក្នុងមូលដ្ឋានរបស់ខ្លួន ហើយចំណុចចាប់ផ្ដើមដើម្បីឈានទៅរកភាពជោគជ័យនៅមូលដ្ឋាន គឺ ផ្ដើម

ចេញពីខ្លួនយើងម្នាក់ៗ ព្រោះបើប្រពលរដ្ឋទាំងអស់មិនចូលរួមនៅក្នុងដំណើរការអភិវឌ្ឍនៅមូលដ្ឋានទេ គឺ គ្មានថ្ងៃ ឃុំ សង្កាត់ និង ប្រទេសជាតិមានការរីកចម្រើន និង អភិវឌ្ឍ។

ជារួមការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិឃុំ សង្កាត់ តាមបែបវិមជ្ឈការ ប្រាកដជាផ្តល់នូវផលប្រយោជន៍ដ៏មហាសាលដល់ ប្រជាជនកម្ពុជា ព្រោះថានេះជានយោបាយកែទម្រង់ដ៏ល្អមួយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និង ពង្រីកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ហើយក៏មានការលើកកម្ពស់ការចូលរួម និង ភាពជាម្ចាស់នៅមូលដ្ឋាន។ ជាពិសេសការចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និង ការកាត់បន្ថយភាពក្រីក្ររបស់ ប្រជាពលរដ្ឋ។

ដំណើរការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ សង្កាត់ តាមបែបវិមជ្ឈការនេះ ទោះជាមានអត្ថប្រយោជន៍ជាច្រើន ប៉ុន្តែវាក៏មានបញ្ហាមួយចំនួន ដែលត្រូវយកសិក្សាផងដែរ ព្រោះវាប៉ះពាល់ដល់ ការអនុវត្តនៅក្នុងឃុំ សង្កាត់ ។ លិខិតបទដ្ឋានគតិយុត្តជាច្រើនត្រូវបានរៀបចំ និង ដាក់ឲ្យប្រើប្រាស់ក៏ ពិតមែន ប៉ុន្តែនៅខ្វះខាតលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនទៀត ដូចជា យុត្តសាស្ត្រស្តីពីការផ្ទេរមុខងារដល់ រដ្ឋបាលឃុំ សង្កាត់ យុត្តសាស្ត្រស្តីពីការគ្រប់គ្រង និង អភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលឃុំសង្កាត់ លក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ គោលនយោបាយ ច្បាប់ និង លិខិត បទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនិង ការប្រមូលចំណូលរបស់ឃុំ សង្កាត់។ ទន្ទឹមនេះ លិខិតមួយចំនួនមិន ទាន់ស៊ីសង្វាក់ និង មិនទាន់ស្របតាមគោលនយោបាយវិជម្ឈការឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ លើសពីនេះទៅទៀតក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់មិនសូវយកចិត្តទុកដាក់ខ្ពស់រាល់បាតុភាព និង បណ្តឹងគ្រប់ប្រភេទ របស់ប្រជាពលរដ្ឋទេ និង ធ្វើការសម្រុះសម្រួលដោះស្រាយទំនាស់ដោយមានការអូសបន្លាយពេលវេលានិង ធ្វើឲ្យទំនាស់នោះមានសភាពធ្ងន់ធ្ងរឡើងៗ។ ចំណែក ការប្រជុំរបស់ក្រុមប្រឹក្សា នៅតាមភូមិនានាមួយៗ គឺ មានលក្ខណៈមិនទៀងទាត់នោះទេ ដែលធ្វើឲ្យ ប្រជាពលរដ្ឋពិបាកក្នុងការបង្ហាញពី ឬ លើកឡើងពីតម្រូវការ និង ផលវិបាករបស់ខ្លួនដើម្បីឲ្យមានការ ដោះស្រាយជូនពួកគាត់ ជាពិសេសគម្រោងអភិវឌ្ឍឃុំ សង្កាត់ មិនសូវទទួលបានលទ្ធផលល្អ ព្រោះមិនមានការផ្តល់ស្ទង់មតិរបស់ប្រជាពលរដ្ឋទាក់ទងទៅនិងការអភិវឌ្ឍនោះ ដោយសារតែប្រជាពលរដ្ឋគឺ ជាអ្នកពាក់ព័ន្ធ និង ទទួលនូវសេវាទាំងអស់នោះ។

**អនុសាសន៍** ដោយផ្អែកលើលទ្ធផលខាងលើដែលស្ថិតនៅក្នុងសេចក្តីសន្និដ្ឋាន ហេតុដូចនេះក្នុងនាមអ្នកស្រាវជ្រាវ សុំលើកនូវសំណូមពរមួយចំនួនដូចជា ៖

- បង្កើតច្បាប់ ឬ ចេញអនុក្រឹត្យ ស្តីពីការប្រមូលចំណូលពន្ធដោយផ្ទាល់របស់ ឃុំ សង្កាត់។
- ជំរុញឲ្យមានការប្រជុំចល័តជាមួយប្រជាពលរដ្ឋនៅតាមភូមិនីមួយៗប្រចាំខែឲ្យបានទៀតទាត់។
- បង្កើនការដោះស្រាយវិវាទជូនប្រជាពលរដ្ឋនៅពេលដែលមានវិវាទ។
- ផ្ទេរនូវសិទ្ធិអំណាចជាច្រើនទៀតដល់ឃុំ សង្កាត់ ដែលជាប្រយោជន៍ដល់ប្រជាពលរដ្ឋ។
- មន្ត្រីត្រូវតែប្រកាន់ឥរិយាបថថាខ្លួនជាអ្នកបម្រើដល់ប្រជាពលរដ្ឋ។
- មានលក្ខណៈដោយឡែកសម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាល។
- អភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលឃុំ សង្កាត់ ឲ្យទាន់បច្ចុប្បន្នភាព។
- រាល់សំណូមពររបស់ប្រជាពលរដ្ឋត្រូវតែមានការឆ្លើយតប។
- ផ្តល់ឱកាសឲ្យប្រជាពលរដ្ឋបានលើកឡើងនូវបញ្ហា និង តម្រូវការរបស់ពួកគាត់នៅពេលប្រជុំ។
- ត្រូវមានការស្ទង់មតិរបស់ប្រជាពលរដ្ឋជាមុនសិនមុននិង សម្រេចគម្រោងអភិវឌ្ឍឃុំ សង្កាត់។

# ឯកសារយោង


- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, នស/រកម/០៣០១/០៥, ១៩ មីនា ២០០១។
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, នស/រកម/០៣០១/០៤, ២៧ មិថុនា ២០០៦។
- អនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់, លេខ ១៦ អនក្រ.បក, ២៥ កុម្ភៈ ២០០២។
- អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់, លេខ ២២ អនក្រ.បក, ២៥ មីនា ២០០២។
- អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់, លេខ២៦អនក្រ.បកដ, ០២ មេសា ២០០២។
- អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន, លេខ ១០៣អនក្រ.បក, ២៩ ធ្នូ ២០០០ ។
- កៅ មុយថង. ២០១០. *ការគ្រប់គ្រងរដ្ឋបាលដែនដី,* បោះពុម្ពលើកទី១. ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ។
- កៅ មុយថង. ២០១០. *ប្រព័ន្ធរដ្ឋបាលកម្ពុជា,* ពុម្ពលើកទី១. ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ។
- របាយការបូកសរុបសមិទ្ធផលនៃ ការអនុវត្តការងារក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី២ ( ២០០៧ - ២០១១ )

# ឧបសម្ព័ន្ធ

# ជំពូកទី ១

# ទស្សនៈទានទូទៅស្តីពីវិមជ្ឈការ

# ជំពូកទី ២
# ដំណើរការអនុវត្តការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ជំពូកទី ៣

# របកគំហើញនៃការស្រាវជ្រាវ

# សេចក្ដីផ្ដើម